ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2012, 14:09
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៣៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីស៊ឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វេង ហ៊ិត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ដេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*
លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*
លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន
លោកស្រី អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម
លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ
លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*
លោកស្រី ម៉ុច សុវណ្ណារី
លោកស្រី ទី ស្រ៊ីនណា
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក វ៉េន ពៅ
លោកស្រី ស៊ីន សុវ៉ន
កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*
លោក បាណាបេ ណេគ្វី *(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោកស្រី អង់តា ហ្គិសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| កញ្ញា លី ម៉ាញៀន | អង់គ្លេស |
| លោក នួន ជា | ខ្មែរ |
| កាំង ហ្កេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយលោក ស៊ីលវៀ ខាតវ៉ាយថ៍ ផ្តើមពី........................................................................ទំព័រ ០៩

**ការសួរសំណួរទៅសាក្សី គាំង ហ្គេកអ៊ាវ ហៅ ឌុច**

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................................................ទំព័រ ២២

សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី......................................................................ទំព័រ ២៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគសវនាការដែលបានគ្រោងទុកនៅព្រឹកនេះ អង្គជំនុំជម្រះនឹងដំណើរការសួរចម្លើយជនជាប់ចោទ នួន ជា ពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់លើកយកមកធ្វើសវនាការពិភាក្សាដេញដោលវគ្គពីរ នៃសំណុំរឿង០០២/០១។

នៅក្នុងអង្គហេតុវគ្គពីរ នៃសំណុំរឿង០០២/០១ នេះរួមមានអង្គហេតុនៅក្នុងបរិបទរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ ពីរ គឺអំពីប្រព័ន្ធទំនាក់ទំនងការងារកម្ពុជាប្រជាធិបតេយ្យ ហើយនិងបរិបទទីបី គឺកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងតួនាទី មុខងាររបស់ជនជាប់ចោទ។ ហើយតួនាទី និងមុខងារនោះ គឺមានការទាក់ទងជិតស្និទ្ធទៅនឹងបរិបទទាំងពីរ គឺរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ហើយនិងប្រព័ន្ធទំនាក់ទំនងការងារ។

[០៩:០៤:៣៨]

ទន្ទឹមនឹងនេះដែរ ដោយបញ្ហានេះ វាមានការពាក់ព័ន្ធគ្នា ហើយលំដាប់លំដោយនៃកិច្ចដំណើរការពិភាក្សាដែលអង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីកន្លងមក អំពីកិច្ចប្រឹងប្រែងក្នុងការពិភាក្សាដេញដោលដោយគោរព ឬអនុវត្តនូវគោលការណ៍ទូទៅ ដោយកម្រិតយកតាមដំណើរការដេញដោលតាមលំដាប់លេខរៀងនៃកថាខណ្ឌដែលបានចោទប្រកាន់ចំពោះជនជាប់ចោទនៅក្នុងដីកាដំណោះស្រាយពីលំដាប់លេខរៀងតូចទៅលេខរៀងធំ នេះជាគោលការណ៍រួម។ ប៉ុន្តែដោយសារ នៅក្នុងអង្គហេតុវគ្គពីរនេះ អង្គជំនុំជម្រះពិនិត្យឃើញថា ស្ថានភាព និងភាពពាក់ព័ន្ធរបស់អង្គហេតុទាំងអស់នេះ គឺគប្បីអង្គជំនុំជម្រះធ្វើការកំណត់ និងជម្រាបដល់ភាគីទាំងអស់ សូមឲ្យមានការប្រែប្រួលនូវការពិភាក្សាដេញដោលនៅក្នុងអង្គហេតុវគ្គមួយ-- វគ្គពីរ នៃសំណុំរឿង ០០២/០១ ដែលមានបីបរិបទនេះ ដូចតទៅ៖

ដើម្បីធានាឲ្យកិច្ចប្រព្រឹត្តទៅហ្នឹងបានរលូន ចៀសវាងការច្រំដែល ឬក៏ចៀងវាងមានភាពច្របូកច្របល់។ ម្យ៉ាងទៀត ដោយសារអង្គជំនុំជម្រះពិនិត្យឃើញថា អំពីតួនាទី និងមុខងាររបស់ជនជាប់ចោទនេះ គប្បីអង្គសវនាការទាំងមូលបានដឹងជាមុនទន្ទឹមគ្នា ឬក៏បន្ទាប់ពីរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ នោះគឺនាំឲ្យយើងងាយស្រួលនៅក្នុងការពិភាក្សាដេញដោលអំពីប្រព័ន្ធទំនាក់ទំនងការងារ។

[០៩:០៦:២៥]

ដូច្នេះអង្គជំនុំជម្រះកំណត់ថា នៅក្នុងកិច្ចដំណើរការសវនាការដេញដោលវគ្គពីរនេះ គឺចែកចេញជាបីផ្នែក។ ផ្នែកទីមួយ គឺដេញដោលអំពីរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីកថាខណ្ឌ៣៣ ដល់កថាខណ្ឌ៧១ នៃដីកាដំណោះស្រាយ។ ហើយផ្នែកទីពីរ គឺស្តីអំពីតួនាទី និងមុខងាររបស់ជនជាប់ចោទដែលចាប់ផ្តើមពីរកថាខណ្ឌ៨៦៩ ដល់៨៧២ កថាខណ្ឌ៨៨០ ដល់៨៩២, កថាខណ្ឌ១០០១ ដល់១០១៥, កថាខណ្ឌ១១៣១ ដល់កថាខណ្ឌ១១៤៤, កថាខណ្ឌ១១៤៧ ដល់កថាខណ្ឌ១១៥០ នៃដីកាដំណោះស្រាយ។ ហើយផ្នែកទីបី ស្តីពីប្រពន្ធទំនាក់ទំនងការងារកម្ពុជាប្រជាធិបតេយ្យកថា ខណ្ឌពី៧២ ដល់កថាខណ្ឌ១១២ នៃដីកាដំណោះស្រាយ គឺក្របខ័ណ្ឌនៃវិសាលភាពនៅក្នុងអង្គហេតុទាំងឡាយនៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់យកមកដាក់ពិភាក្សាដេញដោលនៅសម្រាប់វគ្គពីរនៅក្នុងសំណុំរឿង ០០២/០១ គឺនៅដដែលទេ។ គ្រាន់តែមានការផ្លាស់ប្តូរបន្តិចពីលំដាប់អំពីតួនាទី និងមុខងាររបស់ជនជាប់ចោទហ្នឹងយើងរំកិលមកៗជាផ្នែកទីពីរវិញ ហើយអំពីប្រព័ន្ធទំនាក់ទំនងការងារយើងដាក់ទៅគឺទីបីវិញ។ គឺលំដាប់ទីបី ប៉ុណ្ណឹងទេ។ ខ្ញុំគិតថា ទំនងជាអាចស្តាប់បានហើយភាគីទាំងអស់ដោយសារបញ្ហានេះមិនមែនជាអីប្រែប្រួលអ្វីទេ។

[០៩:០៨:២៦]

លោកចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ សូមប្រគល់ភារកិច្ចជូនលោកស្រីចៅក្រមដើម្បីបញ្ជាក់បន្ថែមអំពីការប្រែប្រួលនៃការពិភាក្សានេះ ក្រែងលោភាគីដែលប្រើប្រាស់ភាសាអង់គ្លេស លោកស្តាប់មិនយល់អំពីការប្រែប្រួលនូវលំដាប់កិច្ចពិភាក្សារបស់យើង។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធានបានជម្រាបជូនហើយ គឺថាមានការប្រែប្រួលតិចតួចទេ នៅក្នុងពេលវេលានៃការសាកសួរនេះ គឺផ្នែកទីមួយទាក់ទងទៅនឹងរចនាសម្ព័ន្ធ ទាំងពីថ្នាក់មជ្ឈិម និងថ្នាក់កណ្តាល។ យើងមានពីកថាខណ្ឌ៣៣ ទៅ៧១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដំណាក់

កាលបន្ទាប់និយាយអំពីតួនាទី និងមុខងាររបស់ជនជាប់ចោទទាំងបីនាក់។ ខ្ញុំមិនមានកថាខណ្ឌជាក់លាក់នៅចំពោះមុខខ្ញុំទេ ប៉ុន្តែតាមដែលយើងដឹងគឺថា ជនជាប់ចោទ នួន ជា ពាក់ព័ន្ធពីកថាខណ្ឌ៨៦៩ ទៅដល់៨៩២ និងពីកថាខណ្ឌពាក់ព័ន្ធបន្តបន្ទាប់ទៀត។ ហើយមុននឹងយើងចូលទៅដល់កថាខណ្ឌ៧២ ទៅដល់កថាខណ្ឌ១១២ និយាយអំពីប្រព័ន្ធនៃការទំនាក់ទំនងដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ លោកប្រធាន និងខ្ញុំបានពិភាក្សាគ្នា និងបានជម្រាបជូនភាគីច្បាស់លាស់ហើយ តើច្បាស់លាស់ទេ? សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត បង្គាប់ទៅអនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះនេះ។

សូមអញ្ជើញលោកមេធាវី!

[០៩:១០:៥២]

**លោក ម៉ៃខល ផេសមិន៖**

បាទ សូមជម្រាបថា កូនក្តីរបស់ខ្ញុំមុននឹងចូលមកឈើរង្វង់រាងក្រចកសេះ គឺសូមសំណូមពរតូចមួយទេ។ ទីមួយ គឺខ្ញុំមិន-- ខ្ញុំសូមថាឲ្យសួរសំណួរជាក់លាក់ ហើយកូនក្តីរបស់ខ្ញុំនេះ គឺចង់ធ្វើសេចក្តីថ្លែងខ្លីមួយទេ ដែលនេះចាត់ទុកជាសារណាមួយមុននឹងគាត់ឆ្លើយទៅនឹងសំណួរទាំងឡាយ។ ប្រហែលជាត្រូវការពី១០ ទៅ១៥នាទីទេ។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះមេត្តាអនុញ្ញាតឲ្យកូនក្តីខ្ញុំសូមអាននូវសេចក្តីថ្លែងការខ្លីទេ មុននឹងគាត់ឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា។ សូមអរគុណ។

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងវង់ក្រចកសេះ)*

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១២:៤០]

**ប្រធានអង្គជំនុំ៖**

មុននឹងសម្រេចលើបញ្ហាសំណើសុំនេះ អង្គជំនុំជម្រះសូមសួរទៅលោក នួន ជា ថាតើលោកមានការប៉ុនប៉ងធ្វើសេចក្តីថ្លែងការណ៍នេះ វាពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌនៃអង្គហេតុទាំងឡាយដែលអង្គជំនុំជម្រះកំណត់លើកយកមកធ្វើសវនាការដេញដោលសម្រាប់វគ្គពីរ នៃសំណុំរឿង០០២/០១ នេះដែរឬទេ ឬក៏ជាបញ្ហាផ្សេងដោយឡែកពីនេះ?

**លោក នួន ជា៖**

សូមគោរពលោកប្រធាន មានការពាក់ព័ន្ធ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់មេធាវីការពារក្ដី នួន ជា ហើយនិងភាគីដទៃទៀតជ្រាបផងដែរថា កិច្ចដំណើរការសួរដេញដោលចំពោះជនជាប់ចោទ គឺនឹងចាប់ផ្ដើមដោយអង្គជំនុំជម្រះមុន មិនដូចការសួរសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកជំនាញ ដែលយើងបានតែងតែតែងតាំងភាគីដែលជាអ្នកស្នើសុំដាក់ឲ្យសួរមុនភាគីដទៃទៀត មុនទាំងអង្គជំនុំជម្រះផង។ ប៉ុន្តែចំពោះជនជាប់ចោទត្រូវសួរដោយអង្គជំនុំជម្រះមុនភាគីដទៃទៀត។

អញ្ជើញលោក នួន ជា!

[០៩:១៥:៤១]

**លោក នួន ជា៖**

សូមគោរព ពុកម៉ែ បងប្អូន រួមជាតិទាំងអស់ក្នុងទីនេះ ទូទាំងប្រទេស និងក្រៅប្រទេស។ សូមគោរពលោកប្រធានជាទីគោរព! យើងទាំងអស់គ្នានៅទីនោះប្រកាសថា ស្វែងរកយុត្តិធម៌ និងការពិតជូនប្រជាជនកម្ពុជាទាំងមូល។ ក៏ប៉ុន្តែការពិតនៅទីនេះ មិនបានបម្រើដល់រូបភាពប្រវត្តិសាស្ត្រមួយពេញលេញ និងត្រឹមត្រូវសម្រាប់ឲ្យប្រជាជនកម្ពុជាយល់ដឹងពីអ្វីដែលនៅពីក្រោយហេតុការណ៍ដែលបានកើតឡើងនោះទេ។

ខ្ញុំនៅតែប្រៀបធៀបអ្វីដែលតុលាការកំពុងតែដេញដោលនេះ គឺជាខ្លួនក្រពើ តែមិនយកក្បាលនិងកន្ទុយដែលជាបំណែកសំខាន់ក្នុងការបម្រើដល់សកម្មភាពរាល់ថ្ងៃរបស់វាមកពិភាក្សា ឬក្នុងន័យម្យ៉ាងទៀត គឺថា ឫសគល់ និងបច្ច័យរបស់វា គឺជាអ្វីដែលបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ តែតុលាការនេះ មិនយកមកពិចារណា។

លោក លោកស្រីចៅក្រមជាទីគោរព! តើអង្គជំនុំជម្រះនេះអាចពិចារណាពីសកម្មភាពរបស់ខ្ញុំដោយមិនពិចារណាដល់កាលៈទេសៈនយោបាយ សង្គម និងបរិបទប្រវត្តិសាស្ត្រទូលំទូលាយជាងនេះនៅពេលដែលកម្ពុជាប្រជាធិបតេយ្យចូលកាន់អំណាចដូចម្ដេចទៅ? យើងត្រូវតែពិនិត្យ និងយល់ពីរបបដ៏ពុករលួយ ភាពអត់ឃ្លាន ការបំផ្លិចបំផ្លាញ ភាពក្រីក្រ ការស្លាប់បាត់បង់ជីវិត អំពើពុករលួយ ជំងឺរាតត្បាត ភាពវឹកវរ និងអំពើហិង្សា ដែលមាននៅក្នុងប្រទេសកម្ពុជានៅមុនរបបកម្ពុជាប្រជាធិប

តេយ្យ។ យើងត្រូវតែពិនិត្យមើលផងដែរ ពីការទម្លាក់គ្រាប់បែករបស់អាមេរិក ដែលមិនគ្រាន់តែសម្លាប់ប្រជាជនស្លូតត្រង់កម្ពុជារាប់សែននាក់ប៉ុណ្ណោះទេ តែថែមទាំងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា និងសៀងផងដែរ។

[០៩:១៩:០៣]

យើងត្រូវតែពិនិត្យស្ថានភាពដ៏អាក្រក់របស់ប្រទេសកម្ពុជាទាំងមូល នៅមុនខែមេសា ឆ្នាំ១៩៧៥ ដែលទទួលរងនូវការបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ និងដោយគ្មានដំណើរការប្រព័ន្ធសុខាភិបាល។ ទាំងនេះគឺជាអង្គហេតុទាក់ទងដ៏ត្រឹមត្រូវជាក់លាក់មួយសម្រាប់តុលាការនេះ ត្រូវតែពិចារណាឲ្យបានពេញលេញ និងហ្មត់ចត់បំផុត។ ជាងនេះទៅទៀត នៅពេលវាយតម្លៃពីអំពើរបស់ខ្ញុំ គេត្រូវពិនិត្យបញ្ហាបន្ថែមថា តើប្រទេសរបស់ខ្ញុំត្រូវបានបំផ្លាញដោយយន្តហោះទម្លាក់គ្រាប់បែក បេ-៥២ ដែរឬអត់? នៅពេលវាយតម្លៃពីអំពើរបស់បុគ្គលម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យមើលបញ្ហាថា តើគាត់ត្រួតត្រាទីក្រុងដ៏ស្អាត និងស្រស់ឆើតឆាយដែរឬអត់? ឬជាទីក្រុងដែលធ្លាក់ចូលក្នុងការអត់ឃ្លានទៅហើយនោះ? នៅពេលវាយតម្លៃអំពើរបស់មេដឹកនាំម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យមើលបញ្ហាថា តើប្រទេសជិតខាងមួយដែលក្នុងករណីនេះ គឺប្រទេសវៀតណាមពិតជាបានព្យាយាមបន្តនយោបាយឈ្លានពាន វាទទី លេបទឹកដី និងបំបាត់ពូជសាសន៍មកលើប្រទេសកម្ពុជាដែរឬអត់?

និយាយដោយសង្ខេបទៅ យើងមិនអាចយល់ពីអំពើ និងការខកខានរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានទេ ប្រសិនបើយើងមិនបានពិនិត្យមើលបរិបទខាងប្រវត្តិសាស្ត្រ និងសង្គមសាស្ត្រដែលត្រូវបានអនុវត្ត-- ដែលត្រូវបានអនុវត្តនៅឡើយ។

[០៩:២២:០៣]

លោក លោកស្រីចៅក្រម អង្គជំនុំជម្រះសាលាដំបូង អាចកែតម្រូវចំណុចខ្វះខាតទាំងនេះ ដោយអនុញ្ញាតឲ្យមានការស្ដាប់ចម្លើយសាក្សីមួយចំនួនដែលក្រុមយើងខ្ញុំបានស្នើសុំ។ ខ្ញុំចង់ឲ្យស្ដាប់ចម្លើយសាក្សី ដោយស្ថិតនៅទីក្រុងភ្នំពេញនៅមុនពេលការចាប់កំណើតរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យគាត់ពន្យល់តុលាការ និងសាធារណជនថា តើស្ថានភាពនៅក្នុងទីក្រុងភ្នំពេញនៅពេលនោះ វាពិតជាអាក្រក់យ៉ាងដូចម្ដេច? ខ្ញុំចង់ស្ដាប់ការផ្ដល់សក្ខីកម្មរបស់មន្ត្រីយោធាអាមេរិកនៅពេលនោះ ដើម្បីបានឮការវាយតម្លៃរបស់ពួកគេ អំពីការខូចខាតដែលបណ្ដាលមកពីការវាយប្រហារ ដោយគ្រាប់ បេ-៥២ របស់គាត់។ មិនតែប៉ុណ្ណោះ ខ្ញុំចង់ស្ដាប់ចម្លើយសាក្សីដទៃទៀតដែលអាចផ្ដល់បរិបទពាក់ព័ន្ធទៅនឹងសកម្មភាពនានា

ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងមូល ជាពិសេសយុវជនជំនាន់ក្រោយដើម្បីឱ្យយល់ដឹងថា អ្វីដែលជាអំពើ និងមិនមែនអំពើរបស់កម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមស្នើថា ប្រធានបទប្រវត្តិសាស្ត្រដូចខាងក្រោមនេះ ត្រូវតែលើកយកមកពិភាក្សាដេញដោលក្នុងសវនាការមួយជាសាធារណៈ។

[០៩:២៤:២៨]

១) ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកយ៉ាងដំណំមកលើប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៦៥ ដល់ ឆ្នាំ១៩៧៣។ រួមទាំងការរាប់ចំនួនប្រជាជនស៊ីវិលដែលបានស្លាប់ដោយការទម្លាក់គ្រាប់បែក និងការបំផ្លិចបំផ្លាញដល់ហេដ្ឋារចនាសម្ព័ន្ធមានដូចជា ផ្លូវថ្នល់ ប្រព័ន្ធទូរគមនាគមន៍ និងលទ្ធភាពផលិតខាងកសិកម្មជាដើម។

២) គ្រោះទុរភិក្ស និងភាពអត់ឃ្លានដែលបានកើតឡើងទ្រង់ទ្រាយធំនៅប្រទេស-- នៅក្នុងប្រទេសកម្ពុជា រួមទាំងទីក្រុងភ្នំពេញផង នៅមុនខែមេសា ឆ្នាំ១៩៧៥។ ព្រមទាំងការគិតគូរផងដែរអំពីចំនួនជនភៀសខ្លួន អំពីលក្ខខណ្ឌរស់នៅ និងមូលហេតុដែលនាំឱ្យមានការរត់ចោលផ្ទះ។

៣) បរិមាណអាហារដែលមាន និយាយឱ្យចំ គឺអង្ករនៅក្នុងទីក្រុងភ្នំពេញនៅភ្លាមៗមុនខែមេសា ឆ្នាំ១៩៧៥ និងលទ្ធភាពខាងកសិកម្មសម្រាប់រយៈពេលខ្លី និងវែងនៅក្នុងអំឡុងពេលនោះ។

[០៩:២៦:២៩]

៤) អំពីវិស័យសុខាភិបាលនៅខែមេសា ឆ្នាំ១៩៧៥ និងជំនួយមនុស្សធម៌អន្តរជាតិដែលអាចមាននៅក្នុងអំឡុងឆ្នាំ១៩៧០ ដល់១៩៧៥ ដោយរាប់បញ្ចូលទាំងជំនួយដែលផ្តល់ដោយសហរដ្ឋអាមេរិកផង។

៥) និងពីតួនាទីពាក់ព័ន្ធរបស់វៀតណាមមកលើប្រទេសកម្ពុជា ជាពិសេសកម្ពុជាប្រជាធិបតេយ្យ។

លោក លោកស្រីចៅក្រមជាទីគោរព! បញ្ហាទាំងអស់នេះមិនមែនជាប្រធានបទដែលខ្ញុំទើបតែលើកមកនិយាយក្នុងពេលនេះទេ។ មេធាវីរបស់ខ្ញុំក៏បានស្នើដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតឱ្យស៊ើបអង្កេតទៅលើប្រធានបទដ៏សំខាន់ទាំងនេះសម្រាប់ការពិត និងមានប្រយោជន៍នេះដែរ។ តែភាពលម្អៀង និងការព្រងើយកន្តើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានបំពេញនូវសំណើដ៏មានប្រយោជន៍ទាំងនេះទេ។ នេះគឺជាការខាតបង់មួយយ៉ាងធំធេង និងធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះតុលាការនេះយ៉ាងខ្លាំងដែរ។

[០៩:២៨:១៧]

ភាពលម្អៀងរបស់ការិយាល័យមួយនេះ ដែលធ្វើការស៊ើបអង្កេតសម្រាប់តែការដាក់បន្ទុក ដើម្បីផ្គាប់ចិត្តការិយាល័យសហព្រះរាជអាជ្ញា គឺជាការអាម៉ាស់មួយដែលយើងទាំងអស់ដឹងឮ និងមិនអាចទទួលយកបានទេ។ រឹតតែច្បាស់ទៅទៀតនោះ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ចៅក្រមស៊ើបអង្កេតគ្មានសរសេរមួយពាក្យណាសោះទាក់ទងនឹងប្រធានបទខាងលើនេះ។ ហើយដូចតែគ្នាទេ ដែលនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ក៏ខកខានមិនបានលើកឡើងពីប្រធានបទនេះដែរ។ ដូចដែលខ្ញុំបាននិយាយហើយ ដោយមានបញ្ជាពីសហ-- ដោយមានបញ្ជាពីសហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេតដោយឯករាជ្យនោះទេ។

[០៩:២៩:៤៥]

អាស្រ័យហេតុនេះហើយ យើងខ្ញុំមានតែពឹងផ្អែកតែទៅលើសហចៅក្រមស៊ើបអង្កេតនេះឯងតែប៉ុណ្ណោះ។ យើងខ្ញុំបានធ្វើសំណើសុំឲ្យមានការស៊ើបអង្កេតលើបញ្ហាបរិបទទាំងនេះ ឲ្យបានទូលំទូលាយជាច្រើនដង។ ប៉ុន្តែសំណើរបស់យើងខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សម្រាកសិន-- លោក នួន ជា ផ្អាកសិន លោក នួន ជា មានការតជំទាស់ពីសហព្រះរាជអាជ្ញា។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់សេចក្តីប្រកាសរបស់ជនជាប់ចោទ។ ខ្ញុំអត់ធ្មត់រង់ចាំស្តាប់ ថាតើនៅក្នុងសេចក្តីប្រកាសរបស់គាត់នោះ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលដែរឬទេ? ជនជាប់ចោទត្រូវបានអង្គជំនុំជម្រះសួរហើយ ថាតើមានពាក់ព័ន្ធដែរឬទេ? គាត់បញ្ជាក់ថាពាក់ព័ន្ធ។ ក៏ប៉ុន្តែនៅពេលនេះ គឺគាត់ហាក់ដូចជាតវ៉ាមិនពាក់ព័ន្ធទៅនឹងចំណុចនោះ ដូចដែលគាត់បានលើកឡើងកាលពីមុន។ នៅក្នុងទឡ្ហីករណ៍នេះ ដែលយើងខ្ញុំកត់សម្គាល់ឃើញ ដោយសារតែអង្គជំនុំជម្រះរបស់យើងបានពិចារណាដេញដោលរយៈពេលពីរខែហើយ ទៅលើបញ្ហាប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ហើយជនជាប់ចោទត្រូវបានសួរសំណួរមួយចំនួន ហើយក៏មានការសួរសំណួរអំពីកុមារភាព និងការធ្វើដំណើរនៅព្រំដែន ដោយមានការណែនាំដោយ ហេង សំរិន ជាដើម។ ដូច្នេះ យើងឃើញថាមានឯកសារប្រាំមួយនៅក្នុងបញ្ហាប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែជនជាប់ចោទ គាត់មិនឆ្លើយតបទៅនឹងឯកសារទាំងអស់នោះ។

[០៩:៣១:៤៧]

ខ្ញុំលើកឡើងនេះ គឺឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីផងដែរ ដែលថាការលើកឡើងរបស់គាត់នោះ គឺមានលក្ខណៈចម្លែក ហើយជនជាប់ចោទនៅពេលនេះ គឺហាក់ដូចជាគាត់លើកឡើងសេចក្តីប្រកាសរបស់គាត់ពាក់ព័ន្ធទៅនឹងអង្គច្បាប់ ជាជាងអង្គហេតុដែលវាជាប់ទាក់ទងទៅនឹងអង្គវគ្គរបស់យើងក្នុងដំណាក់កាលក្រោយនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារជនជាប់ចោទ!

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមិនចង់លើកទឡ្ហីករណ៍ឆ្លើយតបនោះទេ។ ក៏ប៉ុន្តែ កូនក្តីនេះរបស់ខ្ញុំនេះ រៀបនឹងបញ្ចប់សេចក្តីប្រកាសរបស់គាត់រួចទៅហើយ។ ដូច្នេះ យើងខ្ញុំស្នើសុំឱ្យគាត់បញ្ចប់សិនទៅ អ្វីដែលគាត់លើកឡើងនេះ គឺពាក់ព័ន្ធទៅនឹងកថាខណ្ឌនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ ដូច្នេះ បញ្ឈប់នូវសេចក្តីថ្លែងការណ៍របស់ នួន ជា ដែលបានធ្វើអម្បាញ់មិញនេះ ត្រឹមនេះ។ ហើយជម្រាបលោក នួន ជា ផងដែរ ថាប្រសិនបើសេចក្តីថ្លែងការណ៍លើកក្រោយ លោកមានបំណងស្នើសុំ លុះត្រាតែសេចក្តីថ្លែងការណ៍ជាប់ពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ដេញដោល សម្រាប់វគ្គនីមួយៗ។ អម្បាញ់មិញនេះ មុននឹងចាប់ផ្តើមដំណើរការពិភាក្សាដេញដោល យើងពិតជាបានរំឭកឡើងវិញ ភាគីទាំងអស់ឱ្យផ្តល់នូវគំនិតបញ្ញាស្មារតី ដើម្បីសួរដេញដោលនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលបានចោទប្រកាន់បរិបទចំនួនបី គឺ រចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ តួនាទីមុខងាររបស់ជនជាប់ចោទដែលមានកំណត់នៅក្នុងកថាខណ្ឌជាក់លាក់មួយចំនួន ហើយនិងអំពីប្រព័ន្ធទំនាក់ទំនងការងារ។ អម្បាញ់មិញនេះ យើងក៏បានស្តាប់ដែរ ឃើញថា មិនមានចូលទៅក្នុងអង្គហេតុទាំងឡាយដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការដេញដោលនៅក្នុងអំឡុងពេលនៃចាប់ផ្តើមការពិភាក្សាដេញដោល ដែលកំណត់ហៅថាអង្គហេតុវគ្គពីរនៃសំណុំរឿង០០២/០១ នោះឡើយ។

[០៩:៣៤:៤២]

ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រគល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសាកសួរសំណួរ ចំពោះជនជាប់ចោទ នួន ជា។

លោកមេធាវី យើងលែងអនុញ្ញាតឲ្យលោកធ្វើអ្វីទៀតហើយ នេះជានីតិវិធីរបស់តុលាការដែលត្រូវធ្វើដេញដោលចំពោះជនជាប់ចោទ នួន ជា អំពីបរិបទនៃអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនធ្វើការកត់សម្គាល់និងសេចក្ដីសន្និដ្ឋាននោះទេ។ ខ្ញុំសូមសម្រាកប្រាំនាទីដើម្បីធ្វើការពិភាក្សាជាមួយនឹងកូនក្ដីរបស់ខ្ញុំ ដើម្បីពិភាក្សាអំពីផលវិបាកដែលកើតចេញពីសេចក្ដីសម្រេចនេះ។ ដូច្នេះ ខ្ញុំត្រូវការពេលវេលាពិភាក្សាជាមួយកូនក្ដីរបស់ខ្ញុំ។ សូមអរគុណ។

[០៩:៣៥:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៦:២១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ មេធាវីនិងកូនក្ដីរបស់លោក គឺមានពេលវេលាគ្រប់គ្រាន់ ពីព្រោះប្រធានបទដែលអង្គជំនុំជម្រះបានកំណត់នេះ គឺបានដាក់ជូនលោកយូរណាស់ហើយ តាមអនុស្សរណៈផ្សេងៗដែលអង្គជំនុំជម្រះបានកំណត់ ហើយមិនត្រឹមតែប៉ុណ្ណោះទេ មុននឹងបញ្ចប់នូវកិច្ចដំណើរការសវនាការចុងក្រោយនៃសប្ដាហ៍មុន អង្គជំនុំជម្រះក៏បានជម្រាប រំឭកជូនដល់ភាគីទាំងអស់នៃគោលបំណងកិច្ចដំណើរការសវនាការនៅក្នុងសប្ដាហ៍នេះដែរ។ ជាពិសេស គឺយើងបានកំណត់យ៉ាងច្បាស់លាស់នៅពេលវេលាសម្រាប់ដេញដោលចំពោះជនជាប់ចោទ ហើយនិងកិច្ចដេញដោលពិភាក្សាចំពោះបុគ្គលផ្សេងទៀតដែលជាសាក្សីនៅក្នុងរឿងក្ដីនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមសួស្ដី! អរុណសួស្ដីលោក នួន ជា។ អរុណសួស្ដីលោក នួន ជា ខ្ញុំសូមនិយាយនៅពេលចាប់

ផ្ដើមនេះថា អង្គជំនុំជម្រះបានយល់អំពីហេតុផលរបស់លោកពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងមុនឆ្នាំ១៩៧៥។ ក៏ប៉ុន្តែ នៅក្នុងថ្ងៃនេះយើងផ្ដោតជាដំបូងដោយផ្ទាល់តែម្ដងទៅលើរចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិម និងថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ទៅ។ កាលពីប៉ុន្មានសប្ដាហ៍មុនយើងបានពិភាក្សាដេញដោលយ៉ាងលម្អិតទៅលើការងារដែលលោក និងលោក ទូ សាមុត ដែលលោកបានធ្វើការងារបង្កើតយុទ្ធសាស្ត្រ និងយុទ្ធវិធីសម្រាប់បក្ស ហើយខ្ញុំយល់យ៉ាងពេញលេញ ការងារនោះគឺជាការងារសំខាន់ សម្រាប់បក្សកុម្មុយនីស្ដកម្ពុជា។ ហើយលោកបានដឹងអំពីប្រវត្តិ យុទ្ធវិធី និងយុទ្ធសាស្ត្ររបស់បក្ស។ លោកក៏បានជម្រាបផងដែរថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បក្សបានអនុម័តនូវលក្ខន្តិកៈមួយ ហើយនៅពេលនេះ ខ្ញុំចង់សួរទៅលើលក្ខន្តិកៈដែលបានប្រើប្រាស់ដោយបក្សកុម្មុយនីស្ដកម្ពុជាចាប់ពីឆ្នាំ១៩៧៥ តទៅ។

[០៩:៣៩:២៧]

នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រង់កថាខណ្ឌ៣៣ បានលើកឡើងថា លក្ខន្តិកៈថ្មីបានអនុម័តនៅក្នុងឆ្នាំ១៩៦០ លោកបានគិតថា នៅពេលដែលយើងពិភាក្សាកាលពីប៉ុន្មានសប្ដាហ៍មុន លោកបានគិតថា អាចអនុម័តមួយខែ ឬក៏ពីរខែក្រោយឆ្នាំនោះ។ ក៏ប៉ុន្តែលោកបានឯកភាពថា គឺជាលក្ខន្តិកៈរបស់បក្សដែលបានអនុម័តហើយប្រើប្រាស់ដោយបក្សចាប់ពីឆ្នាំ១៩៧៥មក។ នៅពេលនេះ ខ្ញុំសូមផ្ដល់នូវលក្ខន្តិកៈដដែលនោះជាភាសាខ្មែរ ហើយខ្ញុំចង់ឲ្យលោកជួយពន្យល់ឲ្យខ្ញុំយល់ ចំណុចនៅក្នុងផ្នែកនៃលក្ខន្តិកៈបក្សដែលបានសរសេរ។ ខ្ញុំជឿថា លោកមានតួនាទីមួយសំខាន់ និងពិសេសជួយឲ្យអង្គជំនុំជម្រះយល់អំពីលក្ខន្តិកៈនោះ។

ឯកសារដែលបានដាក់នៅចំពោះមុខ នួន ជា គឺលក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា E3/130។ ខ្ញុំសូមចាប់ផ្ដើមដោយសួរសំណួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងគោលការណ៍មូលដ្ឋាន និងជំហរនយោបាយរបស់បក្សដែលមានចែងនៅក្នុងផ្នែកទីមួយនៃលក្ខន្តិកៈនោះ។

**សៈ** ជាបឋម ថាតើត្រឹមត្រូវដែរឬទេថា កថាខណ្ឌដំបូងនៅក្នុងលក្ខន្តិកៈនោះនិយាយអំពីបក្សបដិវត្តន៍ថា មានឈ្មោះជាបក្សកុម្មុយនីស្ដកម្ពុជា។ តើត្រឹមត្រូវដែរឬទេ?

**លោក នួន ជា៖**

**ឆៈ** គោរពលោកប្រធាន! ខ្ញុំសូមប្រើសិទ្ធិនៅស្ងៀមសិន រហូតទាល់តែបាននិយាយជាមួយមេធាវី។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៌៖**

ថាតើលោកចង់ពិភាក្សាសំណួរនេះជាមួយនឹងមេធាវីរបស់លោក ឬក៏លោកចង់សួរសំណួរអ្វីផ្សេងទៅនឹងមេធាវី?

[០៩:៤២:២៧]

**លោក ម៉ៃខល ផេសមិន៖**

គឺខ្ញុំមិនឲ្យសួរសំណួរនេះទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៌៖**

អង្គជំនុំជម្រះបានធ្វើសេចក្ដីសម្រេចរួចមកហើយ ហើយខ្ញុំចង់បញ្ជាក់បំភ្លឺឲ្យបានច្បាស់លាស់ជាមួយនឹងកូនក្ដី នួន ជា។ មេធាវីសូមអង្គុយចុះ!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំគិតថា អង្គជំនុំជម្រះមិនអាចសួរសំណួរនូវអ្វី សំណួរទាំងឡាយណាដែលយើងខ្ញុំមិនទាន់បានពិភាក្សាជាមួយនឹងកូនក្ដីរបស់ខ្ញុំនោះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៤៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ផេសមិន តើលោកត្រូវការពេលវេលាប៉ុន្មានដដែកពិភាក្សាជាមួយនឹងកូនក្ដីរបស់លោក?

**លោក ម៉ៃខល ផេសមិន៖**

ដូចដែលខ្ញុំបញ្ជាក់ ខ្ញុំសូមប្រាំនាទី គឺគ្រប់គ្រាន់ហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកអាចពិភាក្សាជាមួយកូនក្ដីរបស់លោកបានហើយ។

អនុរក្សថយចេញសិនទៅ ឲ្យរក្សាសិទ្ធិក្នុងការនិយាយជាសម្ងាត់រវាងមេធាវីជាមួយនឹងជនជាប់ចោទ កូនក្ដីរបស់គេ។

[០៩:៤៤:៤០]

*(មេធាវីការពារក្ដី ពិភាក្សាជាមួយជនជាប់ចោទ នួន ជា)*

[០៩:៤៧:១២]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យនិយាយ-- ឲ្យខ្ញុំនិយាយដោយសង្ខេបជាមួយនឹងកូនក្ដីរបស់ខ្ញុំ។ យើងខ្ញុំស្នើសុំឲ្យកូនក្ដីរបស់ខ្ញុំ បញ្ចប់សេចក្ដីប្រកាសរបស់គាត់ ចំណាយពេលតែពីរឬបីនាទីតែប៉ុណ្ណោះ។ វាសំខាន់ណាស់ដែលត្រូវតែបញ្ចប់ទៅលើសេចក្ដីប្រកាសដែលក្នុងនោះមានសំណើជូនអង្គជំនុំជម្រះ។ ហើយជនជាប់ចោទ គឺគាត់ចង់លើកសំណើដោយផ្ទាល់មាត់។ ដូច្នេះហើយគាត់គួរតែមានសិទ្ធិ-- គួរតែត្រូវបានអនុញ្ញាតឲ្យលើកសេចក្ដីប្រកាសនោះ។ ខ្ញុំទើបតែពិភាក្សាជាមួយនឹងកូនក្ដីរបស់ខ្ញុំ គាត់បានបញ្ជាក់ថា ប្រសិនបើគាត់មិនអាចបញ្ចប់នូវសេចក្ដីប្រកាសរបស់គាត់នោះទេ គឺគាត់នឹងមិនធ្វើការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ឬក៏អង្គហេតុដែលពាក់ព័ន្ធនៅក្នុងវគ្គនេះពីឆ្នាំ១៩៧៥ ដល់ ៧៩ នោះឡើយ។ សូមអរគុណ។

[០៩:៤៧:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៥:១០]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យ នួន ជា បន្តនូវសេចក្ដីថ្លែងការណ៍របស់ខ្លួន ប្រសិនបើសេចក្ដីថ្លែងការណ៍នោះមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការវគ្គពីរ សម្រាប់សំណុំរឿង០០២/០១ នេះ។

ទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះក៏កត់សម្គាល់អំពីអាកប្បកិរិយារបស់មេធាវីអន្តរជាតិការពារក្ដី នួន ជា ផងដែរ ដែលបានចេញនូវអាកប្បកិរិយាមិនសមរម្យនៅក្នុងកិច្ចពិភាក្សានេះ។

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

សូមអរគុណលោកប្រធាន។ សូមគោរព! ខ្ញុំសូមអានបន្ត៖

ដូចដែលខ្ញុំបាននិយាយហើយ ដោយមានបញ្ហាពីសហចៅក្រមស៊ើបអង្កេត មេធាវីការពារក្ដី មិនត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេតដោយឯករាជ្យនោះទេ។ អាស្រ័យហេតុនេះហើយ យើងខ្ញុំមានតែពឹងផ្អែកតែទៅលើសហចៅក្រមស៊ើបអង្កេតនេះឯងតែប៉ុណ្ណោះ។ យើងខ្ញុំបានធ្វើសំណើសុំឲ្យមានការស៊ើប

អង្កេតលើបញ្ហាបរិបទទាំងនេះ ឲ្យបានទូលំទូលាយជាច្រើនដង។ ប៉ុន្តែសំណើរបស់យើងខ្ញុំ មិនដែលត្រូវបានយកមកពិចារណាទាល់តែសោះ។

[០៩:៥៧:១១]

ការប្រព្រឹត្តរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមកលើសំណើរបស់យើងខ្ញុំ បានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត គ្មានបានជួយអ្វីសោះដល់ខ្ញុំ ធ្វើឲ្យខ្ញុំរហូតមកដល់ពេលនេះ មានតែបាតដៃទទេឡើងមកតទល់ក្នុងសវនាការនេះ។

ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនេះ មិនដូចការិយាល័យសហចៅក្រមស៊ើបអង្កេតទេ។ ហើយរំពឹងថា លោក លោកស្រីចៅក្រម នឹងប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការស្វែងរកការពិត មានប្រយោជន៍ និងយុត្តិធម៌។ អាស្រ័យដោយហេតុផលខាងលើនេះ ខ្ញុំសូមស្នើដល់អង្គជំនុំជម្រះ៖

១) សូមបន្តផ្នែកបរិបទប្រវត្តិសាស្ត្រនៅមុនឆ្នាំ១៩៧៥ ដូចដែលបានរៀបរាប់ខាងលើឲ្យបានហ្មត់ចត់ ទូលំទូលាយ ដើម្បីឲ្យជាតិខ្មែរ និងបរទេសយល់ឲ្យបានច្បាស់លាស់។ ហើយប្រសិនបើអង្គជំនុំជម្រះ នៅតែបន្តទៅផ្នែកមួយទៀតនោះ ខ្ញុំនឹងពិចារណាប្រើសិទ្ធិនៅស្ងៀមរបស់ខ្ញុំ។

២) សូមឲ្យមានការស្តាប់សាក្សី និងអ្នកជំនាញដែលបានស្នើឡើង ដោយមេធាវីរបស់ខ្ញុំបន្ថែមទៀត ដើម្បីជួយដល់តុលាការនេះ សម្រេចបាននូវយុត្តិធម៌មួយពិតប្រាកដ ដែលអាចទទួលយកដោយគ្រប់ភាគី។

៣) និងតាមច្បាប់កម្ពុជា ខ្ញុំសូមស្នើដល់អង្គជំនុំជម្រះ អនុញ្ញាតឲ្យខ្ញុំមានសិទ្ធិដាក់ឯកសារភស្តុតាងថ្មីៗបានគ្រប់ពេលរហូតដល់ចប់ដំណើរការ។ នេះជាអ្វីដែលខ្ញុំស្នើឡើងនៅថ្ងៃនេះ។

[១០:០០:០០]

បញ្ហាមួយទៀត ខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាផ្តល់នូវចម្លើយខ្លះៗពីអ្វីដែលខ្ញុំបានស្នើដោយផ្ទាល់មាត់នៅទីនេះកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។ តើសំណើរបស់ខ្ញុំនេះដែលត្រូវបានលើកយកមកពិភាក្សាដោយអង្គជំនុំជម្រះដែរឬទេ? ព្រោះវាមានរយៈពេលជិតមួយខែមកហើយ តាំងពីសំណើនេះត្រូវបានលើកឡើង។ តែរហូតមកដល់នេះ ពេលនេះ ខ្ញុំមិនទាន់បានចម្លើយណាមួយពីអង្គជំនុំជម្រះសោះ។ សូមលោកប្រធាន មេត្តាផ្តល់ចម្លើយដោយអនុគ្រោះ។ សូមគោរព។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំបានស្តាប់ឮផ្នែកចុងក្រោយរបស់សេចក្តីប្រកាសរបស់លោក នួន ជា ហើយខ្ញុំសូមសម្តែងមតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺថាយើងហាក់ដូចជាមានការព្រួយបារម្ភ ហើយនិងមានការខឹងសម្បាផងដែរ។ យើងយល់ថាភាគីខាងការពារក្តីមានសិទ្ធិ ហើយគឺថាសិទ្ធិទាំងអស់នេះក៏យើងត្រូវប្រៀបធៀបទៅនឹងសិទ្ធិភាគីផ្សេងទៀតផងដែរ។ ពីព្រោះថា យើងអនុវត្តសិទ្ធិទាំងអស់នេះនៅក្នុងក្របខ័ណ្ឌរបស់អង្គ-- ដែលកំណត់ដោយអង្គជំនុំជម្រះ មិនមែនលក្ខខណ្ឌរបស់ក្រុម នួន ជា នោះទេ។

ខ្ញុំឮគាត់និយាយអំពីបរិបទប្រវត្តិសាស្ត្រ ហើយយើងបានពិភាក្សាអំពីបញ្ហាប្រវត្តិសាស្ត្រនេះច្រើនសប្តាហ៍មកហើយ។ ខ្ញុំគិតថាទាំងលោក នួន ជា ទាំងភាគីការពារក្តីនោះមិនត្រូវបានគេជំទាស់ឲ្យនិយាយរឿងបរិបទនេះទេកាលពីពីរបីសប្តាហ៍មុនមកនោះ។ ហើយខ្ញុំភ្ញាក់ផ្អើលណាស់ដែលឥឡូវនេះសូមបន្តនិយាយអំពីបរិបទប្រវត្តិសាស្ត្រទៀត។ ហើយខ្ញុំក៏ចង់បង្ហាញផងដែរថាតើភាគីការពារក្តី ថ្វីត្បិតតែគាត់មានសិទ្ធិមែន ក៏ប៉ុន្តែគាត់មិនត្រូវប្រើសិទ្ធិនេះធ្វើជាការគំរាមកំហែងនោះទេ ព្រោះខ្ញុំសង្កេតឃើញថា លោក នួន ជា បានលើកឡើងថា បើសិនជាមិនចង់ធ្វើអ្វីដែលខ្ញុំចង់បានទេ ខ្ញុំនឹងឈប់និយាយ។

[១០:០៣:១១]

យើងទាំងអស់គ្នាចង់ឲ្យលោក នួន ជា និយាយ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ខ្ញុំមិន-- យល់ឃើញថាយើងត្រូវតែទទួលរាល់លក្ខខណ្ឌដែលគាត់ដាក់មកលើយើងនោះទេ។ នីតិវិធីត្រូវតែបន្ត ហើយធ្វើ-- យើងមិននៅទីនេះដើម្បីតែលោក នួន ជា ទេ គឺថាយើងនៅដើម្បីដើមបណ្តឹងរដ្ឋប្បវេណីដែលយើងការពារផងដែរ។ ហើយខ្ញុំចង់ឲ្យអង្គជំនុំជម្រះជម្រាបជូនទៅដល់លោក នួន ជា ថាគាត់មិនមែនជាអ្នកដាក់លក្ខខណ្ឌមកដល់ជំនុំជម្រះនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ មានភាគីដទៃទៀតមានមតិយោបល់អីទេ បញ្ហានេះ?

[១០:០៤:០២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានការព្រួយបារម្ភដូចគ្នាផងដែរ ការសង្កេតបន្ថែមដែលខ្ញុំសុំលើកឡើងនោះគឺថា របៀបដែលអង្គជំនុំជម្រះត្រូវបន្តទៅមុខនោះ គឺត្រូវតែមានការស្តាប់សាក្សីបន្ថែម-- បន្តទៀតដែលកំពុងតែរង់ចាំមកផ្តល់សក្ខីកម្ម។ ដូច្នេះហើយ នៅពេលដែលសាក្សីទាំងអស់នោះមកផ្តល់

សក្ខីកម្ម លោក នួន ជា អាចធ្វើការលើកឡើងអំពីបញ្ហាប្រវត្តិសាវតារបក្សកុម្មុយនីស្តកម្ពុជាផងដែរ។

គឺៗការលើកឡើងដែលថាមិនអាច គាត់ជនជាប់ចោទ នួន ជា មិនអាចលើកឡើងហេតុការណ៍មុនឆ្នាំ១៩៧៥ នោះគឺមិនត្រឹមត្រូវនោះទេ។ ហើយក្រៅពីចំណុចនេះ គឺខ្ញុំទុកសិទ្ធិ ឆន្ទានុសិទ្ធឲ្យអង្គជំនុំជម្រះធ្វើការដំណើរការនីតិវិធីទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះប្រកាសសម្រាកសែសិបប្រាំនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញ លោកមេធាវីជាតិការពារក្តីឲ្យលោក អៀង សារី!

[១០:០៥:៤៧]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោក លោកស្រីចៅក្រមដោយសារបញ្ហាសុខភាពលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមក្នុងសវនាការដោយផ្ទាល់នៅក្នុងថ្ងៃនេះសម្រាប់ថ្ងៃនេះពេញតែម្តង។ ប៉ុន្តែសូមចូលរួមសវនាការនេះ ដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់ផ្សាយសវនាការនេះ ដោយសូមបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមបន្ទប់ខាងក្រោម បន្ទប់សវនាការនេះតាមប្រព័ន្ធសោតទស្សន៍។ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់នៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ដោយសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ តែសូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោមតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ថ្ងៃនេះ។

[១០:០៧:០១]

តែក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗ នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំជាស្រេចនូវឧបករណ៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា ទៅកាន់កន្លែងកៅអីរបស់គាត់នៅពីក្រោយមេធាវីរបស់គាត់ចុះ។

*(សវនាការសម្រាកពីម៉ោង ១០:០៧ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងប្រគល់វេទិកាទៅឲ្យលោក នួន ជា ដែលបានលើកដៃសុំ។ អង្គជំនុំជម្រះសូមជម្រាបជូនទៅលោក នួន ជា ឲ្យបានជ្រាបថា អង្គជំនុំជម្រះបានពិនិត្យលើសំណើសុំរបស់លោក ដែលបានស្នើសុំកាលពីព្រឹកមិញដល់អង្គជំនុំជម្រះឲ្យដោះស្រាយនូវបញ្ហាចំនួនបួន។

បន្ទាប់ពីបានពិនិត្យលើសំណើសុំទាំងបួនរបស់លោក អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំទាំងនេះ ជាសំណើចាស់ ដែលកន្លងមកត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្ដី នួន ជា និងជនជាប់ចោទ នួន ជា ខ្លួនផងដែរ។ ហើយសំណើសុំមួយចំនួនត្រូវបានអង្គជំនុំជម្រះដោះស្រាយរួចហើយ ហើយសំណើសុំមួយចំនួនទៀតបាននឹងកំពុងតែពិនិត្យពិចារណា។

[១១:០៣:៥៨]

នេះពាក់ព័ន្ធទៅសំណើសុំ ដែលជនជាប់ចោទ នួន ជា បានធ្វើសំណើសុំកាលពីព្រឹកមិញ។ ហើយជាបន្តនេះ គឺអង្គជំនុំជម្រះសូមទៅជនជាប់ចោទ នួន ជា ថា ឥឡូវនេះតើលោកត្រៀមនឹងឆ្លើយនឹងសំណួរដែលចៅក្រមអង្គជំនុំជម្រះនឹងសួរចំពោះលោកដែរឬទេ ចំពោះអង្គហេតុទាំងឡាយដែលអង្គជំនុំ

ជម្រះបានកំណត់ធ្វើសវនាការសម្រាប់វគ្គពីរ នៃសំណុំរឿង០០២/០១នេះ?

លោកឆ្លើយនឹងសំណួរ រួចលោកអាចនិយាយនូវអ្វីដែលលោកលើកឡើង-- លើដែអម្បាញ់មិញនេះ។

អញ្ជើញលោក នួន ជា ឆ្លើយនឹងសំណួរយើង ដែលយើងបានសួរអម្បាញ់មិញ។ ថាតើលោកបានត្រៀមខ្លួន ហើយនិងត្រូវឆ្លើយនឹងសំណួរដែលចៅក្រមនៃអង្គជំនុំជម្រះនឹងតាំងសំណួរចំពោះលោកដែរឬទេឥឡូវនេះ ចំពោះអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់សម្រាប់លើកយកមកធ្វើសវនាការដេញដោល ដែលយើងកំណត់ថា អង្គហេតុសម្រាប់ដេញដោលវគ្គពីរ នៃសំណុំរឿង០០២/០១។

ឆ្លើយនឹងសំណួរនេះសិន។

**លោក នួន ជា៖**

ខ្ញុំសូមអរគុណអង្គជំនុំជម្រះ ដែលបានអនុញ្ញាតឲ្យខ្ញុំបានពិភាក្សាជាមួយមេធាវីរបស់ខ្ញុំ។ អានសំណើរបស់ខ្ញុំរហូតដល់ចប់ ដោយសារពេលនេះ អង្គជំនុំជម្រះបន្តទៅផ្នែកមួយទៀត ហើយដូចដែលនៅក្នុងសំណើរបស់ខ្ញុំ នៅពេលនេះ ខ្ញុំសូមប្រើសិទ្ធិនៅស្ងៀមរបស់ខ្ញុំ ហើយខ្ញុំនឹងពិចារណាឆ្លើយសំណួរវិញ នៅពេលណាខ្ញុំគិតថាសមស្រប។ ខ្ញុំគិតថា ខ្ញុំគួរតែត្រូវបានផ្តល់ឱកាសពន្យល់ទៅប្រជាជនកម្ពុជាថា ការជម្លៀសប្រជាជនចេញពីភ្នំពេញ គឺជាពិតត្រឹមត្រូវ និងជាការចាំបាច់ទៅតាមច្បាប់អន្តរជាតិ។ សូមអរគុណលោកប្រធាន។

[១១:០៦:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដោយលោកជនជាប់ចោទបានបង្ហាញជំហរជាក់ច្បាស់លើបញ្ហារក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយបត។ ឥឡូវនេះ ដំណើរការដែលយើងបានគ្រោងទុកសម្រាប់ធ្វើសវនាការនេះ ក៏មិនអាចទៅមុខបានដែរ ដោយសារអ្វីដែលយើងបានគ្រោងទុកនេះ គឺសម្រាប់ដំណើរការសវនាការជនជាប់ចោទ នួន ជា ប្រើសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសំណួរ។

ដើម្បីដោះស្រាយបញ្ហានេះ ឲ្យបានមានប្រសិទ្ធភាព ហើយជាការសន្សំពេលវេលាក្នុងគោលបំណងសម្រេចដំណើរការចាត់ការរឿងក្តីឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព អង្គជំនុំជម្រះសម្រេចកែប្រែនូវកាលបរិច្ឆេទសម្រាប់សួរស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺចាប់ដំណើរការនៅពេលរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយសាមសិបនាទី។ ដូច្នេះ ភាគីទាំងអស់នៃរឿងក្តីជ្រាប ហើយ

និងអញ្ជើញចូលរួមដើម្បីបន្តកិច្ចដំណើរការសវនាការនៅរសៀលនេះ ដោយចាប់ផ្តើមពីការសួរដេញដោលលើស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់។ ហើយទន្ទឹមនឹងនេះ អង្គជំនុំជម្រះបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងឱ្យនាំជនជាប់ចោទ-- អ៎! នាំសាក្សី កាំង ហ្កេកអ៊ាវ មកកាន់បន្ទប់សម្រាប់សាក្សី នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយសាមសិបនាទី។

ឥឡូវនេះ ពេលវេលាក៏សមល្មមនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះមិនអាចដំណើរការដោយអ្វីដែលបានគិតគូររៀបចំផែនការឃើញថា លែងសមស្របសម្រាប់ដំណើការសវនាការនេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការសវនាការនេះ ត្រឹមនេះ។ ហើយសវនាការលើកបន្តទៅរសៀល ដូចអ្វីដែលអង្គជំនុំជម្រះជម្រាបជូនអម្បាញ់មិញនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:០៩:០៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុចមួយខ្លី។ ដូចដែលមាននៅក្នុងសារណាពាក់ព័ន្ធទៅនឹងបញ្ហា ខៀវ សំផន ស្តីអំពីផលវិបាកក្នុងការផ្តល់សេចក្តីប្រកាសជូនអង្គជំនុំជម្រះ បន្ទាប់មក បដិសេធមិនឆ្លើយតប។ ខ្ញុំគិតថា បញ្ហានេះ គួរតែអនុវត្តចំពោះលោក នួន ជា។ ខ្ញុំគិតថា វាជាបញ្ហាសំខាន់ ដែលអង្គជំនុំជម្រះត្រូវពិចារណាទៅលើចំណុចនេះ ហើយជនជាប់ចោទត្រូវតែជូនដំណឹងទៅដល់-- ជនជាប់ចោទត្រូវតែទទួលការជូនដំណឹងទៅដល់--ដោយអង្គជំនុំជម្រះផងដែរ ពាក់ព័ន្ធទៅនឹងការមិនឆ្លើយតបរបស់គាត់ទៅនឹងសំណួរ។ ដូច្នេះ ហើយគឺថាតើចំណុចនេះ គួរតែអនុវត្តទៅកាន់លោក នួន ជា ផងដែរឬក៏យ៉ាងម៉េច? ចំណុចនេះ យើងត្រូវតែពិចារណានៅពេលព្រឹកនេះ ហើយយើងត្រូវតែសម្រេចឱ្យបានលឿនតាមដែលអាចធ្វើទៅបាន ហើយអង្គជំនុំជម្រះគួរតែជូនដំណឹងទៅដល់ជនជាប់ចោទអំពីផលវិបាកដែលកើតចេញពីការមិនឆ្លើយតបទៅនឹងសំណួរនានា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងអង្គុយសិនចុះ!

[១១:១០:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១១:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយការសង្កេត ឬក៏កត់សម្គាល់របស់សហព្រះរាជអាជ្ញាអន្តរជាតិលើបញ្ហាដែលជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ បញ្ហានេះ អង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំជម្រះ បាននឹងកំពុងតែរៀបចំនូវបញ្ហាឆ្លើយតបទៅនឹងករណីនេះហើយ ហើយការដែលរៀបចំនឹងឆ្លើយនឹងករណីនេះ អង្គជំនុំជម្រះគិតថា សេចក្ដីសម្រេចនោះគឺនឹងសមស្របទៅគ្រប់ករណីទាំងអស់ចំពោះជនជាប់ចោទ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុង អ.វ.ត.ក យើងនេះ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទពីររូបទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនៅរសៀលនេះបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកកាន់សាលសវនាការ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:១២ នាទី ដល់ម៉ោង ១៤:០៨ នាទី)*

[១៤:០៨:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលនេះ ដោយមានការប្រែប្រួល កាលពីព្រឹកមិញ អង្គជំនុំជម្រះនឹងដំណើរការស្ដាប់សក្ខីកម្មសាក្សីឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងបណ្ដឹងអង្គហេតុនៅក្នុងបរិបទសំណុំរឿង០០២/០១។

ក្រឡាបញ្ជី តើសាក្សីរូបនេះមានចំណងទាក់ទងញាតិលោហិត ឬក៏ញាតិពន្ធជា-- ដូចជាឪពុកម្ដាយ បុព្វញាតិ កូន ឬក៏បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ដែរឬទេ? ហើយទីពីរ ថាតើសាក្សីរូបនេះបានស្បថរួចហើយឬនៅ?

សែ កុលវុឌ្ឍី!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវមកផ្តល់សក្ខីកម្មនៅល្ងាចនេះ មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សាក្សីរូបនេះពុំមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងអស់ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយនោះទេ។ សាក្សីនឹងមកធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

[១៤:១០:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មុននឹងបន្តដល់នីតិវិធីនៃការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច អង្គជំនុំជម្រះសូមជម្រាបជូនទៅជនជាប់ចោទ-- អង្គជំនុំជម្រះកត់សម្គាល់អំពីសំណើពាក់ព័ន្ធទៅនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ អៀង សារី និង ខៀវ សំផន ឯកសារ E164 និង E174 អនុលោមតាមមាត្រា៣៥ថ្មី ត្រង់ចំណុច(ឆ) ជនជាប់ចោទមិនត្រូវបានបង្ខំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[១៤:១១:៣១]

បាទ ដោយសារមានការភ័ន្តច្រឡំលើការពិភាក្សាអម្បាញ់មិញនេះ ឥឡូវនេះគឺមតិយោបល់របស់ចៅក្រមផ្សេងទៀត គាត់យល់ថាបញ្ហានេះទុកសម្រេចនៅពេលក្រោយ។ អ៊ីចឹងមុននឹងកោះហៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចូលបន្ទប់សវនាការ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីធ្វើសេចក្តីថ្លែងការណ៍ក្នុងនាមជាអង្គជំនុំជម្រះដំបូង ចំពោះបញ្ហាដែលកើតមានឡើងកាលពីព្រឹកមិញ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១៤:១២:១៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចង់ធ្វើសេចក្តីថ្លែងការណ៍ដូចតទៅនេះ ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅក្នុងសវនាការកាលពីព្រឹកមិញនេះ។ អង្គជំនុំជម្រះសាលាដំបូងសូមរំឭកទៅដល់ភាគី ហើយនិងមេធាវីទាំងអស់ថា ខ្លួនត្រូវបានជម្រាបឲ្យដឹងមុនអំពីកម្មវត្ថុនៃសវនាការនៅថ្ងៃនេះ។ ហើយកម្មវត្ថុនេះ គឺត្រូវបានរំឭកឡើងវិញនៅពេលបើកកិច្ចពិភាក្សាដេញដោលនៅព្រឹក

មិញនេះ។

អង្គជំនុំជម្រះសាលាដំបូងមានចេតនាពិនិត្យផ្នែកនៃសេចក្តី-- នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងនៅថ្នាក់មជ្ឈិម ក៏ដូចជានៅថ្នាក់ជាតិ។ ហើយក៏ពាក់ព័ន្ធទៅនឹងតួនាទី និងទំនួលខុសត្រូវរបស់ជនជាប់ចោទនីមួយៗនៅក្នុងរចនាសម្ព័ន្ធនេះ ក៏ដូចជានៅក្នុងប្រព័ន្ធទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរយៈពេលដែលពាក់ព័ន្ធ។

[១៤:១៣:២៧]

អាស្រ័យហេតុនេះហើយបានជានៅពេលដែលមេធាវីរបស់ជនជាប់ចោទ នួន ជា គឺលោកមេធាវី ផេសមិន បានស្នើសុំឲ្យកូនក្តីរបស់ខ្លួនអាចលើកឡើងនូវសេចក្តីថ្លែងការណ៍ដោយសង្ខេបមុនពេលដែលយើងចាប់ផ្តើមពិនិត្យមើលទៅលើអង្គហេតុនោះ លោកប្រធានបានសួរគាត់ឲ្យគាត់បញ្ជាក់ថាតើសេចក្តីប្រកាសរបស់គាត់នោះ ពាក់ព័ន្ធទៅនឹងប្រភេទនៃអង្គហេតុដែលត្រូវបាន ដែលនឹងត្រូវពិនិត្យជាបន្ទាន់នៅក្នុងក្របខ័ណ្ឌនៃសវនាការនេះដែរឬទេ?

នៅពេលដែលអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនលោក នួន ជា ប្រកាសថា សេចក្តីថ្លែងការណ៍របស់ខ្លួននោះមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់នោះ នៅខណៈដែលខ្លឹមសារពាក្យពេចន៍ទាំងស្រុងរបស់គាត់ គឺនិយាយអំពីប្រភេទនៃអង្គហេតុដែលពិនិត្យរួចមកហើយនៅក្នុងដំណាក់កាលមុននៃសវនាការ។ មេធាវីការពារក្តី នួន ជា នោះ បានជំរុញឲ្យជនជាប់ចោទធ្វើបង្កឲ្យអង្គជំនុំជម្រះមានការភ័ន្តច្រឡំ។ លោកប្រធានអង្គជំនុំជម្រះសាលាដំបូងបានកាត់ផ្តាច់នូវការអាននូវសេចក្តីថ្លែងការណ៍ នៅពេលដែលមានការលេចឡើងបង្ហាញឲ្យឃើញថា វាមិនមានភាពពាក់ព័ន្ធអ្វីទាល់តែសោះទៅនឹងអង្គហេតុដែលនឹងត្រូវពិនិត្យនោះ។ ពេលនោះមេធាវីរបស់លោក នួន ជា បានបញ្ជាក់ថា កូនក្តីរបស់គាត់ ត្រូវតែអនុញ្ញាតឲ្យបន្តនូវសេចក្តីថ្លែងការណ៍របស់ខ្លួន ហើយគាត់ដល់ថ្នាក់បញ្ជាក់អះអាងថា ប្រសិនបើមិនអនុញ្ញាតនោះទេ កូនក្តីរបស់ខ្ញុំនោះមុននឹងឆ្លើយតបទៅនឹងសំណួរណាមួយ ដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា ឬក៏តួនាទីរបស់គាត់ក្នុងអំឡុងរយៈពេលដែលស្ថិតនៅចន្លោះឆ្នាំ៧៥ រហូតដល់ឆ្នាំ៧៩នោះទេ។

[១៤:១៥:២១]

ដូច្នេះ ដើម្បីអនុញ្ញាតឲ្យមានលទ្ធភាពជាអតិបរមានៅក្នុងការបញ្ចេញយោបល់ទៅលើអង្គហេតុដែលនឹងត្រូវពិនិត្យនោះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យ នួន ជា ឲ្យធ្វើសេចក្តីថ្លែងការណ៍

បញ្ចប់របស់ខ្លួន។ ក៏ប៉ុន្តែពាក្យពេចន៍បន្តរបស់លោក នួន ជា នោះនៅតែមិនបង្ហាញនូវភាពពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការនេះទេ។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាមេធាវីរបស់ នួន ជា ព្យាយាមនិងបង្ខំឱ្យអង្គជំនុំជម្រះផ្លាស់ប្តូរនូវរបៀបនៃការដឹកនាំនីតិវិធីរបស់ខ្លួន ឬក៏ចង់ក្រឡុកអង្គជំនុំជម្រះតាមរបៀបមួយមិនសមរម្យ។ អ្វីដែលបានប្រព្រឹត្តនេះ គឺផ្ទុយទៅនឹងវិធាននៃករណីកិច្ចសាស្ត្រដែលមេធាវីនៅចំពោះមុខតុលាការនេះត្រូវតែអនុវត្ត។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមប្រកាសថា អាកប្បកិរិយារបស់មេធាវីដែលពាក់ព័ន្ធនេះ គឺប៉ះពាល់ទៅនឹងបញ្ហាករណីកិច្ចសាស្ត្រ។ ដូច្នេះអង្គជំនុំជម្រះរក្សាសិទ្ធិនៅក្នុងការចាត់វិធានការទៅតាមលក្ខណៈសមស្រប ដើម្បីឆ្លើយតបទៅនឹងការប្រព្រឹត្តបែបនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញ កាំង ហ្គេកអ៊ាវ ចូលមកកាន់បន្ទប់សវនាការ។

[១៤:១៧:០០]

*(សាក្សី កាំង ហ្គេកអ៊ាវ ចូលមកក្នុងបន្ទប់សវនាការ)*

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៩:៣៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

សួស្តីលោក កាំង ហ្គេកអ៊ាវ!

អង្គជំនុំជម្រះសួរអំពីសាវតារជាតិរបស់លោកជាមុនសិន ជាបឋម ហើយនឹងជម្រាបអំពីសិទ្ធិនិងករណីកិច្ចមួយចំនួនដែលពាក់ព័ន្ធទៅនឹងលោក ដែលចូលមកចំពោះមុខអង្គជំនុំជម្រះពេលនេះ ក្នុងនាមជាសាកក្សី។

**ស៖** តើលោកមានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច អ៊ីចឹងមែនដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** បាទ ខ្ញុំបាទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច អ៊ីចឹងមែន។

**ស៖** លោក កាំង ហ្គេកអ៊ាវ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានទេថា តើលោកកើតនៅ

ថ្ងៃខែឆ្នាំណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំកើតនៅថ្ងៃ១៧ វិច្ឆិកា ១៩៤២។

**ស៖** តើទីកន្លែងកំណើតរបស់លោកនៅកន្លែងណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំកើតនៅភូមិពោវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។

[១៤:២០:៥៣]

**ស៖** មុនពេលចាប់ឃុំខ្លួនលោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធានមុនពេលចាប់ខ្លួនខ្ញុំ ខ្ញុំបាទ នៅភូមិអូរទន្ទឹម ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមានកូនបួននាក់។

**ស៖** តើលោកមានជំនឿ ឬក៏កាន់សាសនាអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំកាន់សាសនាគ្រឹស្ត។

**ស៖** អរគុណលោក កាំង ហ្គេកអ៊ាវ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការដែលបានរាយការណ៍ជូនអង្គជំនុំជម្រះអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកបានដឹង គឺលោកមិនមានឪពុកម្តាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងថ្លៃ ប្អូនថ្លៃ ប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តីនេះទេ។ ហើយក៏មិនមានចំណងទាក់ទងជាមួយនឹងគូភាគីនៅក្នុងរឿងក្តីនេះដែរ តើពិតមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពិត។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីណែនាំសាក្សីរូបនេះ ធ្វើសម្បថមុខអង្គជំនុំជម្រះមុនពេលឲ្យគាត់ផ្តល់សក្ខីកម្ម។ លោកស្រី សែ កុលវុឌ្ឍី!

**ក្រឡាបញ្ជី៖**

លោក កាំង ហ្គេកអ៊ាវ សូមលោកដាក់ដៃឆ្វេងនៅលើព្រះគម្ពីរ ហើយសូមលើកដៃស្តាំឡើងលើ ហើយនិយាយតាមខ្ញុំ។

[១៤:២២:៣៩]

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

**លោក កាំង ហ្កេកអ៊ាវ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនឹងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក កាំង ហ្កេកអ៊ាវ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួន មានន័យថា ដោយសារតែចម្លើយ ឬសេចក្តីអត្ថាធិប្បាយរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ នេះជាសិទ្ធិហ្នឹង ហើយក្នុងនាមលោកជាសាក្សី គឺមានកាតព្វកិច្ចត្រូវតែនិយាយការណាដែលពិតដែលខ្លួនបានដឹង បានឮ បានឃើញ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលកើតមានឡើង ហើយដែលត្រូវបានតាំងសំណួរដោយភាគីនានានៅក្នុងរឿងក្តីនេះ។ លោក យល់ដែរ ឬទេ?

[១៤:២៤:០២]

**លោក កាំង ហ្កេកអ៊ាវ៖**

ជម្រាបប្រសាសលោកប្រធាន ខ្ញុំយល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សហព្រះរាជអាជ្ញាជាការអនុញ្ញាត-- អ៊ំ!ជាការអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះ-- អ.វ.ត.ក នឹងតាមអនុស្សរណៈចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០២ (ស៊ីក) របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E172/5 ដែលបានចាត់តាំងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ មុនភាគីឯទៀតពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាំងបីរូប។

អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចមានលទ្ធភាពនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៤:២៥:០០]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ក្នុងអំឡុងពេលនៃការសួរសំណួរដល់សាក្សី លោក កាំង ហ្កេកអ៊ាវ នៅពេលនេះ គឺសហការីរបស់ខ្ញុំ លោក វីល្លៀម ស្មីត ហើយនិងខ្ញុំហ្នឹង នឹងដឹកនាំការសួរសំណួរ ដោយធ្វើការបែងចែកជាប្រាំមួយផ្នែកសំខាន់ៗ។ ហើយដំបូង ខ្ញុំនឹងចាប់ផ្តើមសួរសំណួរដែលពាក់ព័ន្ធទៅនឹងការណែនាំខ្លួនឲ្យស្គាល់សាក្សីរូបនេះ ហើយនិងបង្ហាញអំពីបទពិសោធន៍និងចំណេះដឹងផ្ទាល់របស់គាត់ ដែលមានចំពោះមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងគោលនយោ-បាយរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈសាវតារការងាររបស់គាត់ និងការជាប់ទាក់ទងរបស់គាត់ទៅនឹងបក្ស ថាតើយ៉ាងណាខ្លះ។

[១៤:២៥:៥១]

បញ្ហានេះគឺរួមបញ្ចូលនូវការភ្ជាប់ទំនាក់ទំនងយូរអង្វែងរបស់គាត់ ហើយនិងទំនាក់ទំនងជិតស្និទ្ធរបស់គាត់ ជាមួយនឹងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ចំពោះគោលនយោបាយទាំងអស់របស់បក្ស ដែលចេញពីទស្សនទានរបស់គាត់ រហូតដល់ការជួលរលំនៃទីក្រុងភ្នំពេញ និងអំឡុងពេលបន្តបន្ទាប់មកទៀត។

បន្ទាប់ពីការសួរអំពីការណែនាំខ្លួនសាក្សីរូបនេះហើយ ខ្ញុំនឹងសួរសំណួរអំពីគោលនយោបាយចម្បងៗរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដែលគោលនយោបាយទាំងនេះមានដូចជា ការជម្លៀសប្រជាជនដោយបង្ខំ ការកម្ទេចខ្មាំង និងការអប់រំកែប្រែ ពលកម្មដោយបង្ខំ និងការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។ នៅក្នុងការសួរសំណួរនេះ ខ្ញុំនឹងលើកឡើងនៅក្នុងកថាខណ្ឌនានា ដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានដាក់ចេញមក ដូចដែលមាននៅក្នុងឯកសារលេខ E124/7.2 ដែលមានចំណងជើងថា បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ទាក់ទងនឹងដំណាក់កាលដំបូងនៃសំណុំរឿងលេខ ០០២ ដែលហៅថា ០០២/០១។

[១៤:២៧:១៨]

ហើយបន្ទាប់មកទៀត សហការីរបស់ខ្ញុំ គឺលោក វីល្លៀម ស្មីត គាត់នឹងបន្តសំណួរទៅលើសាក្សីរូបនេះអំពីរចនាសម្ព័ន្ធរដ្ឋបាល និងរដ្ឋាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងរចនាសម្ព័ន្ធទាក់ទង

ការងាររបស់បក្ស និងវិធីដែលរចនាសម្ព័ន្ធនេះត្រូវបានអនុវត្តនៅក្នុងរបបនោះ។ បន្ទាប់មកទៀត គាត់នឹងសួរសំណួរទាក់ទងទៅនឹងតួនាទីផ្សេងៗទៀតរបស់ជនជាប់ចោទទាំងបី ដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធទាំងនេះ។ ហើយជាចុងក្រោយ លោក វីវៀន ស្ទីត នឹងបង្ហាញឯកសារមួយចំនួនទៅសាក្សីដើម្បីឲ្យគាត់ពិនិត្យ និងបញ្ជាក់ផងដែរ។

ដូច្នេះ ខ្ញុំចាប់ផ្តើមសួរសំណួរទាក់ទងនឹងប្រវត្តិសាវតារការងាររបស់សាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សួស្តីលោក កាំង ហ្កេកអ៊ាវ! វត្តមានរបស់លោកនៅចំពោះមុខតុលាការនេះ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនលោកអម្បាញ់មិញហើយថា លោកមកនេះគឺក្នុងនាមជាសាក្សី មិនមែនមកក្នុងនាមជាជនជាប់ចោទទេ។ ហើយអង្គជំនុំជម្រះបានកោះអញ្ជើញលោកមកទីនេះ គឺដើម្បីឲ្យលោកជួយផ្តល់នូវការពិតដែលមាននៅក្នុងសំណុំរឿងនេះ។ តើលោកយល់បញ្ហានេះដែរទេ? ហើយតើលោកសហការជាមួយតុលាការអំពីបញ្ហានេះដែរទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា ខ្ញុំយល់បញ្ហានេះ ហើយត្រៀមខ្លួនជានិច្ចសហការជាមួយតុលាការ។

**ស៖** បាទ សូមអរគុណ។ សំណួរដំបូងរបស់ខ្ញុំគឺចង់ដឹងថា នៅពេលណាដែលលោកបន្តការសិក្សានៅទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំជាប់បាក់អងនៅឆ្នាំ១៩៦២ មករៀននៅវិទ្យាល័យព្រះសីសុវត្ថិពីរឆ្នាំ ឌុបមួយឆ្នាំ។ ដល់១៩៦៤ បានខ្ញុំជាប់បាក់ឌុប ហើយចូលទៅរៀនវិជ្ជាគរុកោសល្យមួយឆ្នាំទៀតបានចេញទៅធ្វើការ។

**ស៖** នៅពេលដែលលោកចេញទៅធ្វើការ គឺលោកធ្វើការលើផ្នែកអ្វីដែរ?

**ឆ៖** ខ្ញុំជាសាស្ត្រាចារ្យគណិតវិទ្យា សាស្ត្រាមធ្យមសិក្សាបឋមភូមិ។

[១៤:៣០:០០]

**ស៖** នៅពេលដែលលោកចាប់ផ្តើមអាជីពជាសាស្ត្រាចារ្យនោះ តើលោក ពេលនោះលោកមានអាយុប៉ុន្មានដែរ? លោកនៅចាំទេ?

**ឆ៖** មើល៍! ខ្ញុំជាប់បាក់ឌុប ឆ្នាំ-- ២២ឆ្នាំ អាយុ២២ឆ្នាំ។ ដូច្នេះអាយុ២៣ ខ្ញុំចេញទៅបង្ហាត់។

**ស៖** បាទសូមអរគុណ។ សំណួរបន្តទៀតសួរថា តើលោកបានទទួលមនោគមន៍វិជ្ជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដំបូងគេ គឺនៅពេលណាដែរ? លោកនៅចាំទេ?

**ឆ៖** ខ្ញុំមានមនោសញ្ចេតនានឹងរបបកុម្មុយនីស្តយូរហើយ ដូចតាំងពីឆ្នាំ១៩៥៥ នៅពេលដែលដឹងដំណឹងថា ម៉ៅ សេទុង បានដោះស្រាយជីវភាពប្រជាជនក្រីក្រនៅប្រទេសចិនឲ្យមានហូបចុក។ ខ្ញុំមានបងប្អូនជីទួតមួយនៅទីនោះ។ ខ្ញុំ ក្រោយមក ដែលសំខាន់បំផុត ខ្ញុំចូលធ្វើបដិវត្តន៍មកពីជំនាន់១៩៦៤ ហ្នឹង មានចលនាបាចខិត្តប័ណ្ណមួយ ដើម្បីប្រកាសជូនប្រជាជនកម្ពុជាថា ឧត្តមសេនីយ៍ លន់ នល់ ធ្វើរដ្ឋប្រហារ ដល់ពេលនុំងបានចាប់ពួកអ្នកបាចខិត្តប័ណ្ណជាង១០នាក់។ ខ្ញុំដែលមានមនោសញ្ចេតនានឹងចលនាបដិវត្តន៍ ក៏សម្រេចចិត្តចូលធ្វើបដិវត្តន៍ ព្រោះមិនចង់សំងំសុខតទៅទៀត។ ដូច្នេះខ្ញុំចូលធ្វើបដិវត្តន៍នៅរវាងខែ១០ ឆ្នាំ១៩៦៤។

[១៤:៣១:៥៨]

**ស៖** បាទ សូមអរគុណ។ តើអ្នកណាដែលជាអ្នកណែនាំលោកឲ្យទទួលស្គាល់នូវមនោគមន៍វិជ្ជាបក្សកុម្មុនីស្តកម្ពុជានេះ? ហើយសូមលោកជួយរៀបរាប់អំពីកាលៈទេសៈទាំងនេះផង?

**ឆ៖** អ្នកដែលខ្ញុំជួបដំបូង គឺមេខ្ញុំតែម្តង គឺលោកគ្រូ សុន សេន។ ប៉ុន្តែខ្ញុំមិនទាន់ជាប់បាក់ឌុប ខ្ញុំជម្រាបគាត់ថា ខ្ញុំអត់ទាន់ចូលរួមទេ។ រួចគាត់អញ្ជើញទៅព្រៃបាត់ទៅ ខ្ញុំជួបជាមួយនឹងក្មេងៗនៅខាងក្រោមទេ។ គឺតាមរយៈ កង សារ៉ន បន្ទាប់មកបាន ឆាយ គឹមហ៊ ហៅ ហុក។

**ស៖** តើលោកមានៗការសម្រេចចិត្តចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា មានមូលហេតុអ្វីថែមពីលើហ្នឹងទៀតដែរទេ?

**ឆ៖** ខ្ញុំសម្រេចចិត្តចូលធ្វើបដិវត្តន៍នៅក្នុងខែ១០ ឆ្នាំ១៩៦៤ ហើយបានរៀនសូត្រ។ ទិញសៀវភៅចម្រើនយកទៅរៀន មានឯកសារបោះ ជាស្នាដៃរបស់ ម៉ៅ សេទុង ខ្លះ ហើយនិងសៀវភៅប្រលោមលោកខ្លះ។ ដល់នៅឆ្នាំ១៩៦៧ រវាងខែកក្កដា នេះ ខ្ញុំបានទៅរៀនសូត្រសម្ងាត់ វគ្គសម្ងាត់នៅផ្លូវលេខ១៦៣ ហួសផ្សារទួលទំពូងបន្តិចទៅ។ ប្រហែលជាពីរខែ បានៗបក្សសម្រេចបញ្ចូលខ្ញុំជាបក្ខជន ហើយនិងបញ្ជូនខ្ញុំទៅជនបទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសកម្មភាពនយោបាយរបស់លោកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង តើលោកបានទទួល ពេលនោះហ៎ តើលោកមានទទួលផលវិបាកអ្វីខ្លះ? ដូចជាមានការចាប់ខ្លួន ឬក៏អ្វីពេលនុំងដែរឬទេបាទ ?

**ផៈ** នៅឆ្នាំ១៩៦៧ នេះ វាមានបញ្ហាពីរ។ បញ្ហាទីមួយគឺ បក្សត្រូវកសាងមូលដ្ឋានឈ្លបនៅជនបទ។ បញ្ហាទីពីរ គឺពួកអនុធនដែលតស៊ូនៅទីក្រុងនេះ វាបែកមុខ។ ដូច្នេះឆ្នាំ១៩៦៧ហ្នឹង បក្សជម្លៀសខ្ញុំ ក៏ដូចអនុធនផ្សេងទៀតទៅជនបទ ដើម្បីម្យ៉ាងការពារសុវត្ថិភាព តែម្យ៉ាងទៀតក៏ដើម្បីជួយកសាងមូលដ្ឋានឈ្លប។ ខ្ញុំទៅដល់ចាប់ផ្តើមការងារនៅថ្ងៃ២៥ ធ្នូ ឆ្នាំ១៩៦៧។ ចាប់ផ្តើមធ្វើសន្និបាតបង្កបង្កើតសាខាមួយនៅស្រុកចម្ការលើ។

ទើបនឹងចប់សន្និបាតហើយ ខ្ញុំក៏ត្រូវចាប់ខ្លួននៅថ្ងៃ២៥-- សូមទោស! ខ្ញុំក៏ត្រូវចាប់ខ្លួននៅថ្ងៃ០៥ មករា ឆ្នាំ១៩៦៨។ ខ្ញុំឆ្លងកាត់ការជាប់ពន្ធនាគារនៅជំនាន់នោះ២៧ខែ។ រហូតដល់ថ្ងៃ០៣ មេសា ឆ្នាំ១៩៧០ ទើបត្រូវបានដោះលែងទៅវិញ ដោយឧត្តមសេនីយ៍ លន់ នល់ ដែលគាត់ធ្វើរដ្ឋប្រហារ។

**សៈ** បាទ សូមអរគុណ។ តើលោកនៅចាំទេថា ការដែលគេចាប់ខ្លួនលោកនៅសម័យនោះ តើលោកត្រូវជាប់ចោទពីបទអ្វីដែលពេលនុ៎ង?

[១៤:៣៥:៤៨]

**ផៈ** បើនិយាយជាភាសាសាមញ្ញ គេហៅថា "ខ្មែរក្រហម"។ ក៏ប៉ុន្តែនៅក្នុងនេះដូចជាគេចោទថា ស្អី? "ចូលជើងចូលដៃជាមួយនឹងបរទេស បំផ្លាញសេចក្តីសុខសាន្តក្នុងព្រះនគរ" អីអ៊ីចឹងទេ ខ្ញុំភ្លេចទៅហើយ។

**សៈ** បាទ សូមអរគុណ។ ចុះបន្ទាប់ពីការដោះលែងលោកចេញពីគុកនុ៎ង តើលោកនៅតែចូលរួមយ៉ាងសកម្មជាមួយនឹងបក្សកុម្មុយនីស្តដដែល ឬក៏យ៉ាងណាដែរ?

**ផៈ** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំនៅតែចូលរួមសកម្ម។

**សៈ** តើលោកបានចូលក្នុងព្រៃ ដើម្បីតស៊ូអីជាមួយអ្នកណាអីដែរទេ?

**ផៈ** ខ្ញុំសូមបញ្ជាក់លោកព្រះរាជអាជ្ញាបន្តិច។ ពីឆ្នាំណា? ឆ្នាំហុក-- ដែលក្រោយខ្ញុំចេញពីគុកហ៎? អរគុណ។ ក្រោយចេញពីគុក ខ្ញុំមកនៅកុដិលេខបី វត្តឧណ្ណាលោម ដែលជាទីស្នាក់អាស្រ័យរបស់ខ្ញុំចាស់ពីមុនមក។ ពីថ្ងៃ-- ក្រោយពីចេញពីគុកបានមួយរយៈ ខ្ញុំមកនៅនឹងកុដិនុ៎ង។ ដើរប្រមូលកម្លាំងដែលជាប់គុកទាំងប៉ុន្មាន ភ្ជាប់ខ្សែឡើងវិញ។ ដល់ថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧០ ទើបខ្ញុំបានចេញតាមផ្លូវព្រែកប្រា ទៅដល់ភូមិថ្មដា ទៅនៅស្នាក់នុ៎ង។ ពេលនុ៎ង កន្លែងនុ៎ងជាតំបន់រំដោះ។

[១៤:៣៧:៤៥]

**សៈ** បាទ សូមអរគុណ។ នៅពេលដែលលោកទៅភូមិព្រែកប្រានោះ តើលោកមានតួនាទីអ្វីដែរ

ពេលនុ៎ង?

**ឆ៖** ខ្ញុំទៅឆ្លងកាត់តាមព្រែកប្រា ចំពុះក្អែក ចុះទៅដល់ភូមិថ្មដា។ មិនទាន់-- នៅជាបក្ខជនធម្មតា ក៏ប៉ុន្តែមិនទាន់មានការងារអីទេ។

**ស៖** នៅពេលដែលលោកចេញទៅថ្មដានោះ តើលោកទៅជាមួយអ្នកណាខ្លះ? ពេលនុ៎ងលោកនៅចាំបានទេ?

**ឆ៖** ជាមួយនឹងខ្សែពួកភ្នំពេញទាំងអស់។ មាន ប៉ុន្តែឥឡូវគ្នាស្លាប់ទៅហើយ មិត្ត ហួន គៀត, សៅ ឆាន ហៅ ឆយ ហើយនិងផ្សេងៗទៀតជាច្រើនដែរទៅនុ៎ង។

[១៤:៣៨:៥៨]

**ស៖** បាទ សូមអរគុណ។ ចាប់តាំងពីពេលដែលលោកចេញទៅតស៊ូនៅទីនោះ រហូតមកដល់ខែមេសា ឆ្នាំ១៩៧៥។ តើលោកធ្លាប់ដែលឃើញ ដែលជួបជាមួយនឹងដូចជា ប៉ុល ពត ឬក៏ នួន ជា, ខៀវ សំផន, អៀង សារី អីដែរទេពេលនុ៎ង?

**ឆ៖** ខ្ញុំមិនដែលជួបទេ។ សូមនិយាយកាត់ទៅចុះ តាមសំណួររបស់លោកក៏កាត់ដែរ។ ខ្ញុំមិនដែលជួបទេ។ ប៉ុល ពត មិនទាំងដែលឮឈ្មោះផង បើ អៀង សារី ខ្ញុំធ្លាប់ឮឈ្មោះ ហើយបើ បងហែម ខៀវ សំផន នេះ ខ្ញុំឮឈ្មោះ ហើយមានមនោសញ្ចេតនាទៅលើគាត់ថែមទៀតផង។

[១៤:៣៩:៥៤]

**ស៖** បាទ អរគុណ។ នៅក្នុងអំឡុងពេលនោះ នៅពេលដែលលោកចេញទៅព្រៃតស៊ូហ្នឹង តើលោកបានដឹងអំពីយុទ្ធសាស្ត្រសង្គ្រាមរបស់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ជាមួយនឹងរបប លន់ នល់ ហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំបានជម្រាបលោកអំមិញហើយ មុននឹងខ្ញុំទៅជនបទ ខ្ញុំរៀនវគ្គសម្ងាត់ ដើម្បីបានចូលបក្ស។ ឯកសារដែលខ្ញុំរៀនពេលនោះ មានលក្ខន្តិកៈបក្ស។ ប៉ុន្តែលក្ខន្តិកៈនុ៎ង ជាលក្ខន្តិកៈឆ្នាំ១៩៦០។ ខ្ញុំបានរៀនអំពីមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្ស និងឯកសារដែលរៀនហ្នឹង សុទ្ធតែឯកសារសម្ងាត់របស់បក្ស។ ហើយនិងទស្សនៈវណ្ណៈ និងការតស៊ូវណ្ណៈ។ ឯកសារសតិអារម្មណ៍អង្គការវិន័យ។ នេះ ជាឯកសារបក្ស ក៏ប៉ុន្តែទន្ទឹមនឹងនេះ ដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញារួចមកហើយ ថាខ្ញុំចូលចិត្តមើលសៀវភៅរបស់ទ្រឹស្តីម៉ៅសេទុង។ ខ្ញុំបានមើលទ្រឹស្តីម៉ៅសេទុងមួយចំនួនដែរ អាហ្នឹង--។

**ស៖** តើលោកនៅពេលនុ៎ង តើលោកបានដឹងយល់ដឹងអំពីយុទ្ធសាស្ត្រយោធាដែលរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងជាមួយនឹងរបប លន់ នល់ អីទេកាលនុ៎ង?

**ឆ៖** ជម្រាបលោកព្រះរាជអាជ្ញា។ ខ្ញុំបានជម្រាបអំមិញហើយថា រឿងខែ មើល៎ ឈប់! រឿងខែកញ្ញា មានខិត្តប័ណ្ណមួយបាច។ ជូនដំណឹងប្រជាជន ជូនព័ត៌មានប្រជាជាថា លន់ នល់ រៀបចំធ្វើរដ្ឋប្រហារ។ ហ្នឹង ខ្ញុំយល់ ក៏ប៉ុន្តែមុននោះ វាមានសភាពការណ៍ អង្កាល់ដែលខ្ញុំរៀននៅថ្នាក់គណិតវិទ្យា។ វាមានរឿងឃាតកបាញ់សម្លាប់ កេណ្ណឺឌី នៅដាឡាស ថ្ងៃ២២ វិច្ឆិកា ១៩៦៤, ៦៤, ៦២១ វាមានព្រឹត្តិការណ៍រដ្ឋប្រហារនៅនែ៎ វៀតណាម ដែល ដួង វ៉ាន់មិញ ធ្វើឃាតក្រុមគ្រួសារ ង៉ោ ឌិញយៀម ខ្មោចខ្មីអស់ ហើយដល់ក្រោយមក ង្វៀន ខាន់ ធ្វើរដ្ឋប្រហារ ដួង វ៉ាន់មិញ ម្តងទៀត។ នេះជាបញ្ហានៅ វៀតណាម។ ដោយឡែក ខង ឡែ នៅឡាវ។ ខង ឡែ គាត់ពាក់សក្តិបីទេ ក៏ប៉ុន្តែគាត់ធ្វើរដ្ឋប្រហារបាន។ ឯកចំណែកនៅថៃ ក៏វាមានរឿង សារិក ថាណារ៉ាត់ នាយករដ្ឋមន្ត្រី។ សេនាប្រមុខ សារិក ថាណារ៉ាត់ នុ៎ង នាយករដ្ឋមន្ត្រីក៏ស្លាប់។ នៅពេលហ្នឹងហើយ ដែលសិស្ស និស្សិតនៅភ្នំពេញ គេគិតថា អាមេរិកាំងប្តូរសេះ។ ហើយសភាពការណ៍នៅពេលនោះទៀត ស៊ីអាតូ ចាប់កំណើតនៅឆ្នាំ១៩៥៤ ដូចជាខែសីហា ដូចថ្ងៃ៨ ខែសីហា។ ខ្ញុំចូលមកហ្នឹង ដល់ភ្នំពេញឆ្នាំ៦២ សកម្មភាពរបស់បេសកកម្មជំនួយយោធាអាមេរិកាំងស្ងាត់ហើយ ក៏ប៉ុន្តែនៅតែឮដំណឹងអំពីសកម្មភាពរបស់ពួក អ៊ុយ.អេស.ស្នាក់ គឺបេសកកម្មជំនួយយោធាហ្នឹង ហើយនិងពួកក្មេងជ្រើមពីរក្រុម។ ពួកស្វូឡិចកង់ស ហើយនិងពួកផ្កាយព្រឹក។ ពួកនេះ គ្មានតួនាទីធ្វើឃាតអ្នកចម្រើន ហើយនិងមន្ត្រីស្លូតត្រង់ស្នេហាជាតិទេ។ គ្រាន់តែមានតួនាទីរំខានចរាចររបស់ពួកអ្នកស្នេហាជាតិ ពួកអតីតតស៊ូ ពួកគណបក្សប្រជាជននិយាយឲ្យចំទៅ។ហ្នឹងមាន ដូច្នេះ សភាពការណ៍ទាំងអស់ហ្នឹង ធ្វើឲ្យចេះតែយល់។ ដូច្នេះ ទន្ទឹមនេះ វាមានព្រឹត្តិការណ៍ សម សារី បែកមុខ គេចទៅបរទេសបាត់។ វាមានព្រឹត្តិការណ៍ ដាប ឈួន។ វាមានព្រឹត្តិការណ៍ ឡាបាត់ ប៉ែកណា ឡាបាត់ (Bernard LABAT) ហើយនិង សុងសាក់ ផានិត បំផ្លាញថវិកាជាតិ។

[១៤:៤៥:០០]

ហើយនិងវាមានព្រឹត្តិការណ៍ឈ្មោះ ផាម វិញគុង ផ្ញើគ្រាប់បែកប្លាស់ស្ទីកចូលព្រះបរមរាជវាំង ប្រាថ្នាធ្វើឃាតព្រះមហាក្សត្រទាំងពីរព្រះអង្គ ក៏ប៉ុន្តែគាប់ជួនព្រះអង្គពេលនោះ មកទទួលភ្ញៀវបាត់មកត្រូវទៅស្លាប់តែព្រះអង្គម្ចាស់នរោត្តម មយុរ៉េន។ ព្រឹត្តិការណ៍ទាំងអស់នេះ ធ្វើឲ្យអ្នកស្នេហាជាតិយល់

បញ្ហាកាន់តែច្បាស់។ នេះអំពីបញ្ហាព្រឹត្តិការណ៍សភាពការណ៍នយោបាយនៅពេលនុ៎ង។

ហ្នឹងហើយដែលជំរុញឲ្យអនុធនមួយចំនួនមានទឹកចិត្តស្នេហាជាតិ។ សុខចិត្តឃើញគេចាប់អ្នកបាចខិត្តប័ណ្ណ ខ្លួនឯងក៏សម្រុកចូលទៅធ្វើបដិវត្តន៍ ដោយគិតថាមិនដឹងជានៅសំងំសុខដល់ណា។ នេះព្រឹត្តិការណ៍ហ្នឹង។ ដូច្នេះនៅឆ្នាំ១៩៦៦ លោកព្រះរាជអាជ្ញាប្រហែលជាចាំហើយ រដ្ឋសភា នីតិកាល ១៩៦៦-៧០ របស់ លន់ នល់ កើតឡើង។ កម្លាំងរបស់ព្រឹទ្ធសភា-- រដ្ឋសភាជំនាន់នុ៎ង ជាកម្លាំង លន់ លន់ សុទ្ធសាធ។ សុំនិយាយ សុទ្ធសាធនេះអ៊ីចុះ លើកលែងតែជនចម្រើនបីនាក់ទេ គឺលោក ខៀវ សំផន នេះមួយ, ហ៊ូ យន់ ពីរ, ហ៊ូ នឹម បី។ ក្រៅពីនោះមានកម្លាំងកណ្តាលម្នាក់ពីរ ដូចជា កៅ សាន នេះជាដើម។ ក្រៅពីនោះសុទ្ធតែកម្លាំងរបស់ពួក លន់ នល់។

[១៤:៤៦:២៨]

ដូច្នេះសភាពការណ៍អស់ហ្នឹង ដែលនាំឲ្យយើងយល់ឃើញថា រដ្ឋប្រហារជិតកើតហើយ។ ពេលនុ៎ង ដល់ លន់ នល់ គាត់កសាងរដ្ឋប្រហារដំបូង-- អ៎សូមទោស រដ្ឋាភិបាលដំបូងរបស់គាត់ ឆ្នាំ១៩៦៦ គាត់ចាប់ផ្តើមកាន់កាប់ជនបទយកទៅឲ្យយោធា ដែលល្បីទូទាំងសកលលោកថា លន់ នល់ គាត់វាតត្បាតកសិករតាមរូបភាពទំនាស់ដីធ្លី តែតាមពិតយើងវិភាគតាមទស្សនៈសង្គ្រាម គឺ លន់ នល់ គាត់ឈានទៅកាន់កាប់ជនបទដោយយោធា។

បក្សពលករកម្ពុជាអង្កាល់នោះនៅឈ្មោះ បក្សពលករកម្ពុជានៅឡើយទេ។ កម្លាំងកងឈ្លបនៅខ្សោយ សម្រេចឲ្យកសិករ ហើយនិងកងឈ្លបគេចមុខសឹក។ តាមពាក្យស្លោកខ្មែរថា “កុំវាំងមុខដឹង កុំទទឹងមុខសឹក”។ កសិករខ្មែរនៅខាងសំឡូត រត់ឡើងភ្នំវ៉ៃចាប ពេលនុ៎ង លន់ នល់ ក៏ត្រូវបង្ខំឲ្យរំសាយរដ្ឋាភិបាល១៩៦៦ របស់គាត់ទៅ។ ក៏ប៉ុន្តែ លន់ នល់ គាត់ចាប់ផ្តើមបង្ក្រាប ពេលនុ៎ងខ្ញុំរៀនវគ្គសម្ងាត់ហ្នឹង ប្រធានសាខារបស់ខ្ញុំ ឆាយ គឹមហ៊ ណែនាំ ថាយើងមិនទាន់ចាប់ផ្តើមសង្គ្រាមប្រជាជនទេ បើសិនជាចាប់ផ្តើមកម្លាំងយើងនៅវាត់រាយ ត្រូវ លន់ នល់ គាត់បង្ក្រាប។ ដូច្នេះយើងរង់ចាំបន្តិចទៀត កសាងមូលដ្ឋានឈ្លបសិន។ នៅពេលហ្នឹងហើយ ដូចខ្ញុំបានជម្រាបលោកសហព្រះរាជអាជ្ញាអ៊ីចឹង ដែលគេបញ្ជូនបញ្ញាជន ដែលបែកមុខចេញពីទីក្រុងទៅនៅជនបទ ដើម្បីជួយកសាងមូលដ្ឋានឈ្លប ហើយនិងដើម្បីការពារសុវត្ថិភាពផង។

[១៤:៤៨:១៧]

ដូច្នេះ សភាពការណ៍វាទៅអ៊ីចឹង។ នៅពេលដែលកងឈ្លបកសាងបានគ្រប់គ្រាន់ហើយ ថ្ងៃ១៨

មករា ឆ្នាំ១៩៦៨ ទើបបក្សសម្រេចរើបុស្ត៍បាយដំរាំ បុស្តិ៍ជីវពលនៅបាយដំរាំ ទុកជាការបើកឆាកធ្វើសង្គ្រាមប្រជាជន។ ឯចំណែកទ្រឹស្តីសង្គ្រាមប្រជាជន ខ្ញុំសូមនិយាយ ថាខ្ញុំអត់ទាន់ដែលបានឃើញទេរហូតដល់ខែ១២ ដែលខ្ញុំទៅនៅខាងស្អាង កោះធំ កៀនស្វាយនេះ ទើបឃើញទ្រឹស្តីឯកសារមួយ ដែលប៉ុល ពត គាត់សរសេរ "សង្គ្រាមប្រជាជនរបស់បក្ស"។ ហើយឯកសារមួយទៀត "យុទ្ធវិធីសង្គ្រាមឈ្លប"។ ហើយឯកសារមួយទៀតឈ្មោះថា នែ៎ "គោលនយោបាយមួយចំនួនរបស់បក្ស"។ ហើយឯកសារមួយទៀត សាមញ្ញខ្លី ក៏ប៉ុន្តែមានន័យខាងវណ្ណៈជ្រៅដែរ "សីលធម៌បដិវត្តន៍"។ ហ្នឹងខ្ញុំសូមបញ្ចប់ពីរឿងកាលដែលបានរៀនសូត្រ ហើយចេះដឹង យល់ដឹងពីបញ្ហានេះ។

[១៤:៤៩:១៩]

**ប្រធានអង្គជំនុំ៖**

មុននឹងបន្ត សូមរំឭកសាក្សី សុំការផ្តល់សក្ខីកម្មឲ្យបានយឺតជាងអម្បាញ់មិញបន្តិច ពីព្រោះការបកប្រែមានបញ្ហាបកមិនទាន់។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកបាននិយាយថា មានមូលដ្ឋានកងឈ្លប មានការបង្កើត តើលោកដឹងថា ពេលនុំងខាងណាខ្លះជាអ្នកដឹកនាំនៅក្នុងមូលដ្ឋានទាំងអស់នោះដែរទេ?

[១៤:៥០:០៣]

**ឆ៖** ខ្ញុំសូមជម្រាបលោកសហព្រះរាជអាជ្ញា ខ្ញុំកាន់ការនៅខាងចម្ការលើបានតែប៉ុន្មានថ្ងៃទេ ពីថ្ងៃ២៥ ធ្នូ ១៩៦៧ ដល់ថ្ងៃ៥ មករា ឆ្នាំ១៩៦៨ ខ្ញុំត្រូវគេចាប់។ ដូច្នេះ ខ្ញុំអត់ទាន់ស្គាល់អីទេ។ ហើយអ្នកដែលនៅជាប់មេខ្ញុំ ជាប់អង្កាល់ហ្នឹងគឺ កែ វិន ៗ ហៅ កែ ពក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបន្តមកសំណួរផ្សេងទៀត ចង់ដឹងថាតើលោកធ្លាប់មានបានធ្វើជាធ្វើការនៅមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្តណាមួយដែរទេ នៅពេលបន្ទាប់មកពីនោះ?

**ឆ៖** មកដល់ភូមិភាគនិរតី ឆ្នាំ១៩៧១ ថ្ងៃ២០ កក្កដា ខាងភូមិភាគពិសេសដែលទើបនឹងចាត់តាំង ភូមិភាគពិសេសហ្នឹង ក៏ទើបហ្នឹងចាត់តាំងដែរ បានប្រគល់នាទីឲ្យខ្ញុំធ្វើជាប្រធានមន្ទីរ១៣។ មន្ទីរ១៣ហ្នឹង គឺមន្ទីរសន្តិសុខ ឬក៏មន្ទីរនគរបាលភូមិភាគពិសេស។ ចាប់តាំងពីថ្ងៃ២០, ២១ កក្កដា ខ្ញុំកាន់ការងារខាងហ្នឹងរហូតមក។

**ស៖** តើលោកនៅចាំដែរទេថាមន្ទីរ១៣ៗហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ធ៖** មន្ទីរ១៣ហ្នឹង មានផ្លាស់ប្តូរទីកន្លែងខ្លះដែរ។ ដំបូងនៅភូមិមួយ ខ្ញុំមិនដឹងបានសួរប្រជាជនផង ភូមិហ្នឹងគេហៅភូមិអី។ ប៉ុន្តែនៅជិតភូមិន៉ែ! ភូមិតាមផ្លូវហ្នឹង គឺភូមិថ្នគុប។ តាមឯកសារដែលហ្វ្រង់ស្វ័រ ប៊ីហ្សូ សរសេរថាអាភូមិហ្នឹង គេហៅភូមិអន្លង់វែង ឬស្អី។ ប៉ុន្តែអាភូមិតាមផ្លូវដែលប្រជាជននៅ គឺគេហៅភូមិថ្នគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ រួចដល់ពីហ្នឹងទៅវាអត់ទឹក ហើយខ្ញុំក៏គិតថាទុកពួកហ្នឹងឲ្យរស់រានមានជីវិតធ្វើស្រែ។ ខ្ញុំក៏ផ្លាស់ចេញពីភូមិនុ៎ងទៅនៅជើងភ្នំពីស ត្រង់ម្តុំកន្លែងមួយ គេហៅថា ទួលស្វាយមាស ហើយនិងតាលាវ ហែកដីស្រែនៅនុ៎ង។

[១៤:៥២:៥៧]

ពេលហ្នឹងហើយ ដែលមានការវ៉ៃគុករត់ឆ្នាំ១៩៧៣។ ខ្ញុំក៏សុំឲ្យ វន វ៉េត គាត់វាសាយដាក់ទោសលើខ្ញុំ ដាក់អនុវត្តវិន័យលើខ្ញុំ តែគាត់មិនព្រម ដល់ក្រោយមក ខ្ញុំមកនៅនឹងត្រង់ភូមិគេហៅថា ន៉ៃ ភូមិត្រពាំងច្រាប រហូតមកដល់១៧ មេសា ៧៥។ តាមពិតដល់រហូត ដល់ថ្ងៃ៣០ មេសា ៧៥ ទើបមេបញ្ជូននេះទៅ។

**ស៖** បាទ សូមអរគុណ។ ក្នុងការដែលលោកទទួលនាទីជាប្រធាន មន្ទីរសន្តិសុខ១៣ហ្នឹង តើអ្នកណាជាអ្នកតែងតាំងលោកឲ្យកាន់ការងារនេះ?

**ធ៖** វន វ៉េត លេខាភូមិភាគពិសេស។

**ស៖** តើលោកស្ម័គ្រចិត្តទទួលយកតួនាទីនេះ អ៊ីចឹងដែរ?

**ធ៖** មិនស្ម័គ្រ។ ធម្មតាទេ ខ្ញុំមិនស្ម័គ្រទេ ប៉ុន្តែវាប្រកែក វាមិនបាន ភារកិច្ចតែបក្សតម្រូវហើយត្រូវតែទទួល។ នេះជារឿងសាមញ្ញនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាបក្សណាដែរ។ បក្សវណ្ណៈអធន គឺអ៊ីចឹង។

[១៤:៥៤:១៧]

**ស៖** បាទ សូមអរគុណ។ សូមលោកជួយរៀបរាប់អំពីមន្ទីរសន្តិសុខនេះបន្តិច ថាតើវាមានមុខងារធ្វើអ្វីខ្លះ ហើយបាទ ?

**ធ៖** មន្ទីរសន្តិសុខ ឬក៏មន្ទីរនគរបាល អង្កាល់ណោះ នៅហៅនគរបាលទេ។ វាមានភារកិច្ចទទួលមនុស្សដែលកងទ័ព វាផ្ញើពីសមរភូមិមកដែលគេចោទថាគិញ យកមកសួរចម្លើយហើយកម្ទេច។ ឲ្យតែចូលតំបន់រំដោះត្រូវចាត់ទុកថាជាខ្មាំង ថាជាគិញ ហើយកម្ទេច។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ខ្ញុំវាមានការស្ទាក់ស្ទើរ មិនអស់មិនហើយ ហ្នឹងហើយបានជាខំទុកមនុស្សបានប្រហែលជា៣០-៤០នាក់

យកទៅ-- ខំរៀបចំហែកដីស្រែថ្មីនៅខាងតាលាវនាំឲ្យកើតមានការរើគុករត់។ នៅពេលនោះហើយដែល អ៊ុង ជឿន គាត់-- អ៊ុង ជឿន តាម៉ុក គាត់ៗជួបខ្ញុំ គាត់ថាមិត្ត ឌុច ត្រូវដាច់ខាត់នោះជាមួយគិញ។ ក្នុងសម័យតស៊ូ ដែលហៅថាសម័យតស៊ូ គឺសម័យឥស្សរៈ សម័យ សឹង ង៉ុកមិញ នោះ។ មកពីមិនដាច់ខាត់ហ្នឹងហើយបានជាយូរៗបាត់បង់ដីរំដោះម្ដងម្ដុំៗ ដូច្នេះមិត្តត្រូវដាច់ខាត។ នៅពេលនុ៎ង ខ្ញុំក៏ទាមទារ វន វ៉េត ឲ្យចែកមន្ទីរម-១៣ ហ្នឹងជាពីរ។ មន្ទីរម-១៣(ក) នៅខាងក្រោយ ខ្ញុំទទួលផ្ទាល់ ហើយមន្ទីរម-១៣(ខ) នៅខាងមុខ មិត្ត ស៊ុំ ទទួល ប៉ុន្តែខ្ញុំនៅតែក្រោមការគ្រប់គ្រងរបស់ខ្ញុំដដែលទេ។

[១៤:៥៦:១៣]

ពួកមន្ទីរម-១៣(ខ)ហ្នឹង សម្រាប់តែទទួលមនុស្សដែលត្រឹមតែម៉ាសង្ស័យៗ ហើយដោះលែងទៅវិញ។ ភាគច្រើនគឺត្រូវដោះលែង យូរៗបានបញ្ជូនទៅម-១៣(ខ) ខាងលើសម្រេចឲ្យបញ្ជូនទៅ ម-១៣(ក)ម្ដង។ នេះប្រវត្តិនៃការរៀបចំហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញហើយថា--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវី!

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន! ខ្ញុំសូមអភ័យទោសដែលបានកាន់ផ្ដាច់ការសួរសំណួររបស់លោកសាក្សីនេះ ក៏ប៉ុន្តែខ្ញុំគិតថា លោកសាក្សីនិយាយលឿនណាស់ ហើយលោកប្រធានក៏បានជម្រាបអម្បាញ់មិញដែរ។ ក៏ប៉ុន្តែនៅក្នុងការបកប្រែជាភាសាបារាំងនោះ គឺថាមានបាត់ខ្លឹមសារច្រើន។ អ៊ីចឹងបើសិនជាសាក្សីអាចព្យាយាមនិយាយឲ្យបានយឺតជាងនេះ ធ្វើយ៉ាងណាដើម្បីកុំឲ្យយើងបាត់ខ្លឹមសារនូវអ្វីដែលគាត់បាននិយាយ។ សូមអរគុណលោកប្រធាន។

[១៤:៥៧:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើននូវការរំឮកនេះ ហើយសូមរំឮកជាថ្មីម្ដងទៀតដល់សាក្សី សូមសម្រួលនូវការពន្យឺតនូវការដែលផ្ដល់សក្ខីកម្មរបស់លោក ដើម្បីឲ្យការបកប្រែភាសាទៅជាភាសាផ្សេងៗ ដែលប្រើប្រាស់នៅទីនេះបានប្រព្រឹត្តទៅបានល្អ ហើយបានយល់ដឹងទាំងអស់គ្នានូវខ្លឹមសារ នូវសក្ខីកម្មដែលលោកបានផ្ដល់។

ហើយឥឡូវនេះក៏ដល់ពេលសមល្មមនឹងសម្រាកដែរហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាក ដប់ប្រាំនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបួន-- អ៎! ម៉ោងបី ដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួលផ្តល់កន្លែងសម្រាក សមរម្យសម្រាប់សាក្សី ហើយនិងអនុរក្សការពារសាក្សីនៅក្នុងអំឡុងពេលសម្រាកផង ហើយនិងឲ្យ នាំគាត់មកកាន់អាសនៈកន្លែងដែលគាត់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ ឲ្យបានមុនអង្គជំនុំជម្រះ ចូលមកកាន់អាសនៈរបស់ខ្លួន។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៨ នាទី ដល់ម៉ោង ១៥:២២ នាទី)*

[១៥:២២:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងប្រគល់វេទិកាជូនទៅ តំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។ ហើយសូមរំឭកឡើងវិញម្តង ទៀតថា សូមនិយាយឲ្យបានយឺតជាងមុនបន្តិច លោក កាំង ហ្កេកអ៊ាវ ដើម្បីសម្រួលដល់ការបកប្រែ ភាសា ដើម្បីឲ្យកិច្ចពិភាក្សារបស់យើងនេះ គឺមានតម្លៃដោយសារមូលហេតុភាគីទាំងអស់ត្រូវតែស្តាប់ បាននូវខ្លឹមសារទាំងអស់គ្នា។ ហើយអរគុណទុកជាមុននូវកិច្ចប្រឹងប្រែងរបស់លោក។

សូមអញ្ជើញ លោកតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកកាំង ហ្កេកអ៊ាវ មុនហ្នឹងយើងបានពិភាក្សាគ្នាអំពីមន្ទីរនគរបាល-១៣។ ឥឡូវសូម ទុកបន្តិច ហើយខ្ញុំចូលមកសំណួរនេះថា នៅពេលៗដែលលោកចេញទៅធ្វើការតស៊ូនៅ-- ចាប់ពីខែ សីហា ឆ្នាំ១៩៧០ ទៅតំបន់រំដោះនោះ រហូតមកដល់លោកធ្វើការងារនៅមន្ទីរនគរបាល-១៣ ហ្នឹង តើ ពេលនោះលោកធ្វើអ្វីខ្លះដែរកាលនុ៎ង?

[១៥:២៣:៥១]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា ដែលបានលើកបញ្ហានេះ។ ខ្ញុំក៏ចង់បញ្ជាក់បញ្ហានេះដែរ។ ដែលហៅថាតំបន់២៥នេះ គឺរួមស្រុកបួន ស្អាង កោះធំ លើកដែក និងកៀនស្វាយ។ ខាងអង្គការខ្មែរនេះ ហៅតំបន់២៥ ក៏ប៉ុន្តែពួកវៀតណាម កងទ័ពវៀតណាមដែលគេមកពីខេត្តអាងយ៉ាងហ្នឹង គេដាក់ឈ្មោះតំបន់នេះថា តំបន់៦២។ តំបន់នេះមុនដំបូងគឺពួកកងទ័ពរបស់ភាគខាងត្បូងវៀតណាមទេគេមករំដោះ។ គេដាក់ថាតំបន់៦២ គេកសាងរដ្ឋអំណាចផ្លូងមួយនៅហ្នុំង។ រដ្ឋអំណាចនេះ ជារដ្ឋអំណាចរបស់បក្សវៀតណាមខេត្តអាងយ៉ាង។ ប៉ុន្តែមានរូបភាពជាខ្មែរ កម្មាភិបាលគណៈតំបន់ជាវៀតណាម តែប្រែឈ្មោះជាខ្មែរ។ “ហាយថាយ” គាត់ប្រែឈ្មោះមកថា ទេព ផាន ហើយកម្មាភិបាលស្រុកក៏ប្រែឈ្មោះមក។ នេះបញ្ហាមួយ។ បញ្ហាមួយទៀត កងទ័ពខ្មែរដែលខាងខេត្តអាងយ៉ាងគេកសាងបានគ្រប់គ្រងដោយគណៈបញ្ជាការអនុសេនាធំវៀតណាម។ មួយស្រុកមានមួយអនុសេនាធំ។ ឯចំណែកជ័យភណ្ឌយុទ្ធភណ្ឌដែលគេរឹបានគេដឹកយកទៅស្រុកគេអស់។ ហ្នឹងជ័យភណ្ឌ យុទ្ធភណ្ឌជារបស់វៀតណាម។ លុយពន្ធដារដែលប្រមូលបាន ក៏ជារបស់វៀតណាម។ ដោយកន្លែងខាងតំបន់២៥ នេះ ជាតំបន់មានវៀតណាមអាចប្រមូលលុយពន្ធដារបានច្រើន វៀតណាមគេចកុករហូតដល់ខែធ្នូ ១៩៧០ ទើបផ្ទេររដ្ឋអំណាចមកឲ្យអង្គការខ្មែរ ទើបមានអង្គការខ្មែរចាត់តាំងឡើងនៅតំបន់២៥ នេះ។

[១៥:២៦:១៣]

នៅពេលដែលវៀតណាមនៅគ្រប់គ្រងតំបន់នេះ ខ្ញុំហើយនិងខ្សែទៅពីភ្នំពេញអត់មានការងារអីទេ។ ខាងវៀតណាមនេះ គេចាប់មិត្ត ឆយ, សៅ ផាន ហៅ ឆយ ហៅ សុវណ្ណ នេះដាក់ឃុំឃាំង។ ចាប់មិត្ត ហួន គៀត ហៅ កែវ សម្បត្តិ នេះដាក់ឃុំឃាំង។ ដល់ខែ១២ ទើបបានផ្លាស់ប្តូរអីចឹងទៅ មានការរៀបចំរដ្ឋអំណាចខ្មែរ។ នៅពេលនេះ ក៏វាមានការខុសគ្នារវាងខ្សែដែរ។ ខ្សែរបស់ សុខ ប៊ុតចំរើន ហើយនិងខ្សែទៅពីក្រុងនេះ វាមិនត្រូវគ្នា។ ខ្ញុំក៏នៅតែអត់ការងារធ្វើដដែលតទៅទៀត។ ប៉ុន្តែដល់ក្រោយមកខ្ញុំត្រូវគេហៅទៅបង្រៀនឯកសារសង្គ្រាមប្រជាជននៅក្នុងកងទ័ព។ កងទ័ពដែលប្រមូលបានខាងអង្គការខ្មែរបានប្រមូលបាននេះ ខ្ញុំជាអ្នកបង្រៀន។ ឯកសារដូចបានជម្រាបសហព្រះរាជអាជ្ញាហើយ គឺសង្គ្រាមប្រជាជន យុទ្ធវិធីសង្គ្រាមឈ្លប សីលធម៌បដិវត្តន៍ ហើយនិងគោលនយោបាយមួយចំនួនរបស់បក្ស។

ដល់ខែប្រាំ ខ្ញុំមើលទៅមានលទ្ធភាពទាក់ទងជាមួយនឹងនាយសេនាធិការ ប្រធានសេនាធិការ កងទ័ពតំបន់២៥ នេះបាន ខ្ញុំសូមអនុញ្ញាតគេមកពីខាងភូមិភាគនិរតី មករកមេចាស់របស់ខ្ញុំអង្គាល់នៅភ្នំពេញនោះ គឺ វន វ៉េត។ ខ្ញុំក៏មក។។ ដូច្នេះនិយាយមួយម៉ាត់នៅតំបន់២៥ នេះ ខ្ញុំស្ថិតនៅជាមនុស្សដែលមិនមានការចាត់តាំងច្បាស់លាស់ទេ។ មកដល់២៥ នេះ -- មកដល់ខាងភូមិភាគនិរតីនេះ ជួបមេចាស់បាន។គាត់ចាត់តាំងជាប្រធាន ម-១៣ នេះ។ ដូច្នេះ ហើយបានរឿងរ៉ាវនៅតំបន់២៥ នេះ ខ្ញុំឃើញ ខ្ញុំដឹង ខ្ញុំឮបានច្បាស់គួរសម។

[១៥:២៨:៤១]

នេះសូមរាប់រៀបត្រួស។តែប៉ុណ្ណេះជូនលោកសហព្រះរាជអាជ្ញា។

**ស៖** បាទ អរគុណ។ មុននឹងយើងសម្រាក មុនហ្នឹងបន្តិចយើងបានពិភាក្សាអំពីថា តើអ្នកណាជាអ្នកតែងតាំងលោក? ហើយឥឡូវសំណួរខ្ញុំបន្តទៀតនេះ គឺ សួរថា ហេតុអីបានជាគេជ្រើសរើសលោកឱ្យទៅកាន់តួនាទីជាប្រធានមន្ទីរនគរបាល ១៣ នេះ?

**ឆ៖** ខ្ញុំពិបាកឆ្លើយណាស់ ក៏ប៉ុន្តែគ្រាន់តែសូមបញ្ជាក់ថា សភាពការណ៍ពេលនោះ នៅខាងនិរតីពួកអនុធនអត់ឱ្យកាន់កងទ័ព អត់ឱ្យកាន់រដ្ឋអំណាចមូលដ្ឋានជាស្រុក សូម្បីតែជាឃុំក៏មិនឱ្យកាន់ដែរ។ មុននឹងបង្កើតភូមិភាគពិសេសនេះ តាម៉ុក គាត់ធ្វើបាបពួកអនុធនហ្នឹងច្រើនហើយ។ មានអនុធនម្នាក់--បួននាក់គឺ ខែក ប៉ែន, កែ គឹមហួត, ជា ហួន ហើយនិង អ៊ុម ឈឿន ត្រូវគាត់ដេញចេញ២៤ម៉ោង។ ប៉ុល ពត សម្រួលឱ្យយកទៅដាក់ខាងពាយ័ព្យ។ អនុធនផ្សេងទៀត គាត់បញ្ឈរជើងចោល។ មានអនុធនម្នាក់ឈ្មោះ ងួន អេង វិស្វករអគ្គិសនី ខឹង តាម៉ុក ខ្លាំងណាស់ ធ្វើបាតុកម្មមិននិយាយ។ សួរស្អីក៏គាត់មិននិយាយ គាត់ថា គាត់គ្រុន។ ដល់គ្រុនទៅវាឡប់-- វាលាប់។គ្រុនទៅ គាត់មិននិយាយ។ ដូច្នេះខ្លាំងណាស់ទំនាស់នៅពេលនុ៎ង។ តាម៉ុក គាត់មានប្រសាសន៍ថា "ធ្វើស្រែស៊ីស្រូវ មើលសៀវភៅស៊ីក្រដាស"។ ឯចំណែកលេខាភាគកាលនុ៎ងមិនមែន តាម៉ុក ទេ ម៉ា ម៉ង់។ ម៉ា ម៉ង់ គាត់មានប្រសាសន៍ថា "កសិករយើងប្រៀបបាននឹងស្មៅ ដុះល្អតែកន្លែងណាដែលគោវាអាចម៍"។ ឆ្នាំ១៩៦៨ ម៉ា ម៉ង់ ត្រូវគេធ្វើឃាតនៅលើកំពូលភ្នំឱរ៉ាល់ ពេទ្យចាក់ថ្នាំច្រឡំ។ ពេទ្យនុ៎ងក្រោយមកក៏មិនរស់ទៀត។

[១៥:៣១:២៧]

ឆ្នាំនោះយើងនៅចាំបានថា ប៉ុល ពត ផ្សព្វផ្សាយឯកសារមួយឈ្មោះថា "សីលធម៌បដិវត្តន៍"។ សីលធម៌បដិវត្តន៍ហ្នឹងមាន១២ "ខ" គាត់មាន១២ប្រការ។ ក៏ប៉ុន្តែក្នុងពេលនេះ ខ្ញុំសូមនិយាយតែប្រការ

មួយទេ គេថា "នៅកន្លែងណាត្រូវបម្រើប្រជាជនកម្មករ កសិករកន្លែងនោះ ឲ្យអស់ពីចិត្តពីថ្លើម"។ សូមបញ្ជាក់ថា ឯកសារនេះបដិវត្តន៍នេះ ខាងការិយាល័យសហព្រះរាជអាជ្ញាដូចមិនៗបានបង្ហាញឲ្យខ្ញុំអធិប្បាយទេ អាចយើងគ្មានផងក៏មិនដឹង។ ប៉ុន្តែអាចរកឯកសារសីលធម៌បដិវត្តន៍នេះបាន នៅក្នុងសៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ (François Ponchaud) ។ ប៉ុងសូដ៍ គាត់បកប្រែអាសីលធម៌១២ប្រការនេះដាក់ក្នុងសៀវភៅគាត់។ ប៉ុន្តែគ្រាន់តែសូមជូនជាការសង្កេតបន្តិច ប៉ុងសូដ៍ យល់ច្រឡំពាក្យខ្មែរខុសមួយម៉ាត់ ក្នុងសីលធម៌១២ប្រការហ្នឹង គេដាក់ "ពលិកម្ម"ៗ គឺការលះបង់ រហូតដល់លះបង់ជីវិត ហើយទៅពលិកម្ម។ ប៉ុន្តែ ប៉ុងសូដ៍ គាត់យល់ថា អាហ្នឹង "ពលកម្ម" គឺធ្វើការងារដោយដៃជើង គាត់បក--

[១៥:៣២:៥១]

**ប្រធានអង្គជំនុំ៖**

ឌុចៗ! ឈប់សិន! កុំអាលសិន!

សូមអញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រីជាទីគោរព។ សំណួរដែលបានសួរដោយសហព្រះរាជអាជ្ញា គឺថាហេតុអ្វីបានជាលោកត្រូវបានគេតែងតាំងជាប្រធានមន្ទីរ ក-១៣។ សាក្សីឆ្លើយថា គាត់មិនដឹងទេ។ ក្រោយមក គឺគាត់លើកឡើងអំពីអង្គហេតុដែលសំខាន់ ហើយមិនពាក់ព័ន្ធទៅនឹងសំណួរដែលបានលើកឡើង។

នៅពេលមួយសហព្រះរាជអាជ្ញាសុំពេលវេលាបន្ថែម ដើម្បីសួរសំណួរសម្រាប់ជនសាក្សីរូបនេះ។ ក៏ប៉ុន្តែប្រសិនបើសាក្សីរូបនេះ អនុញ្ញាតឲ្យលើកឡើងចេះតែបន្តទៅ ទៅលើបញ្ហាដែលមិនពាក់ព័ន្ធទៅនឹងសំណួរនោះ វានឹងចំណាយពេលច្រើនណាស់ ដើម្បីទាញយកភស្តុតាង។

[១៥:៣៣:៥៦]

ខ្ញុំមានការព្រួយបារម្ភ ថានៅពេលដែលយើងធ្វើការតទល់ជាមួយនឹងសាក្សីរូបនេះ យើងខ្ញុំសូមឲ្យគាត់ឆ្លើយចម្លើយត្រង់ៗ ចំៗតែម្តង អាចឲ្យខ្ញុំបន្តទៅមុខ។ ហើយនៅពេលនេះខ្ញុំមិនចង់ធ្វើការកាត់ចម្លើយរបស់សាក្សី និងការសួរសំណួររបស់សហព្រះរាជអាជ្ញានោះទេ។ ហើយប្រសិនបើសហព្រះរាជអាជ្ញា គាត់ចង់សុំសួរបញ្ជាក់បំភ្លឺនោះ អាចសួរសំណួរបន្តបាន។ ដូច្នេះហើយអ្វីដែលសំខាន់នោះ គឺវាជា

ការអៀនខ្មាសអ្វីទេ ប្រសិនបើសហព្រះរាជអាជ្ញាអាចស្តាត់ទៅចម្លើយរបស់សាក្សី នៅពេលដែលសាក្សីគាត់ឆ្លើយចាកចេញឆ្ងាយពីប្រធានបទ។ ជាពិសេសនោះ គឺថាសូមឲ្យចម្លើយនោះឆ្លើយទៅនឹងសំណួរដែលបានសួរ។ សូមអរគុណ។

[១៥:៣៤:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការសង្កេតរបស់មេធាវីការពារក្តីលោក អៀង សារី។ ហើយសូមរំឭកឡើងវិញលោក កាំង ហ្គេកអ៊ាវ នៅក្នុងការផ្តល់សក្ខីកម្ម គឺលោកត្រូវមានកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងសំណួរ។ បានន័យថា ស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបត្រឹមតែខ្លឹមសារសំណួរដែលភាគីហ្នឹងសួរតែប៉ុណ្ណោះ។ លើកលែងតែ ភាគីដែលសួរហើយមានការជំទាស់ពីភាគីដទៃទៀតនោះ គឺអង្គជំនុំជម្រះនឹងសម្រេចអំពីការជំទាស់នុ៎ង ឬក៏ថាឲ្យលោកផ្តល់សក្ខីកម្មឆ្លើយតប ឬក៏មិនចាំបាច់ឆ្លើយតប។ នេះគឺជាការត្រឹមត្រូវ។ ដោយសារកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅ ទីមួយ គឺឲ្យបានឆាប់រហ័ស។ ទីពីរ គឺឲ្យចំបញ្ហា បានន័យថា ឆ្លើយតបជាក់ច្បាស់ទៅនឹងសំណួរ។ ទីបី បញ្ហាមួយទៀត គឺតំណាងសហព្រះរាជអាជ្ញា គឺគប្បីប្រើប្រាស់នៅក្នុងអំឡុងពេលនៃការសួរដេញដោលហ្នឹង គឺកំហិតកំណត់នូវព្រំដែននៃការតាំងសំណួរ ដើម្បីធ្វើម៉េចឲ្យបានចម្លើយហ្នឹងជាក់ច្បាស់។ ដើម្បីឆ្លើយតបទៅនឹងអង្គហេតុងាយយល់ហើយងាយក្តាប់បានផង ហើយនិងបានសំខាន់ទៀតនុ៎ង គឺកាត់បន្ថយពេលវេលា បានន័យថាសន្សំពេលវេលាក្នុងការដេញដោលរឿងក្តីនេះ។ ទោះបីពេលវេលាកម្រិតណាក៏ដោយ ក៏យើងត្រូវតែប្រឹងប្រែងដើម្បីសន្សំពេលវេលានេះ ឲ្យបានលឿនហើយឆាប់រហ័សតាមដែលអាចធ្វើបាន។

សូមអញ្ជើញបន្តនូវសំណួរថ្មីទៀត លោកតំណាងសហព្រះរាជអាជ្ញាជាតិ!

[១៥:៣៦:២០]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំបន្តសំណួរតទៅទៀត ថាតើហេតុអីបានជាលោកទទួលយកតួនាទីនៅ ម-១៣ នោះ? សូមលោកបញ្ជាក់ឡើវិញ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** បាទ ។ បញ្ហាដែលខ្ញុំចង់ជម្រាប គឺបញ្ជាក់ពីបរិបទនយោបាយនៅភូមិភាគនិរតី។ គេមិនចាត់តាំងអនុធន បញ្ញាជនឲ្យកាន់កងទ័ព ឲ្យកាន់គណៈកម្មាធិការមូលដ្ឋានជាស្រុក ជាភូមិ ជាឃុំ ទេ។

ហើយខ្ញុំខំឆ្លៀតយកឱកាសថា បរិបទនយោបាយនៅនិរតី គឺប្រកាន់អ៊ីចឹង។ អ៊ីចឹងហើយ បានៗគេមិនចាត់តាំងខ្ញុំឲ្យធ្វើស្អី។ កងទ័ពគេមិនឲ្យធ្វើ មូលដ្ឋានគេមិនឲ្យធ្វើ គេឲ្យធ្វើនគរបាល។ ហើយមនុស្សដែលតាម៉ុក ផ្ដើលជើងចោលទាំងប៉ុន្មាននេះ ប៉ុល ពត ឲ្យ វន វ៉េត យកមកប្រើជុំវិញមន្ទីរភូមិភាគ។ នេះ បរិបទនយោបាយដែលបង្ខំឲ្យបញ្ញាជនទាំងអស់ ធ្វើការងារមន្ទីរ។ ខ្ញុំមួយផង គេរុញទៅខាងនគរបាល។ នេះ គឺចង់បញ្ជាក់អំពីបរិបទនយោបាយដែលខ្ញុំតម្រូវទៅចូលទៅធ្វើនៅក្នុងនុ៎ង។ ដូច្នេះ ប្រកែកអត់រួចទេ ត្រូវតែធ្វើ។

[១៥:៣៨:០១]

**សៈ** បាទ សូមអរគុណ។ ចូលមកទាក់ទងទៅនឹងលោកបានឆ្លើយមុនហ្នឹងថា អ្នកដែលចាប់ខ្លួនមកមន្ទីរ ម-១៣ គឺសុទ្ធតែជាគិញ។ តើលោកអាចជម្រាបជូនអង្គសវនាការបានទេ ថាគិញនោះ ជាមនុស្សប្រភេទណា? មកពីណា?

**ឆៈ** ខ្ញុំសូមបញ្ជាក់បញ្ហានេះឲ្យច្បាស់។ មនុស្សដែលកងទ័ពគេបញ្ជូនពីមុខ តាមខ្សែរោងយាមមក មកឲ្យ ម-១៣ សួរចម្លើយ ហើយកម្ទេច។ ជាគោលការណ៍របស់បក្សជំនាន់នុ៎ង ឲ្យតែចូលតំបន់រំដោះ អ្នកក្រកក៏ដោយ អ្នកមានក៏ដោយ អ្នកមកទិញមាន់ក៏ដោយ ក៏គេរុញមកឲ្យថាជាគិញ ហើយឲ្យ ម-១៣ សួរចម្លើយ ហើយកម្ទេច។ ដោយហេតុនេះហើយ បានខ្ញុំត្រូវមានទុកមនុស្សមួយចំនួន ដែលខ្ញុំមិនយល់ថាជាគិញ។ មិនត្រឹមតែប៉ុននុ៎ងទេ ខ្ញុំមានសុំដោះលែងរួចប្រហែលជាប្រាំពីរនាក់ ប្រាំបីនាក់ បើតាមខ្ញុំចាំ។ ហើយដល់ក្រោយមក សុំបំបែកមន្ទីរនេះជាពីរ។ ដូច្នេះ គោលការណ៍កំណត់អង្គាល់នុ៎ង ដែលខ្ញុំមិនយល់ស្របជាមួយ គឺឲ្យតែចូលតំបន់រំដោះ គឺត្រូវសន្មតថាជាគិញ។ ហ្នឹងហើយ ដែលខ្ញុំបានជម្រាបសហព្រះរាជអាជ្ញាអំមិញថា តាម៉ុក គាត់ណែនាំខ្ញុំ។ ហើយដែលខ្ញុំជម្រាបតទៅទៀត ដល់ក្រោយមកទៀត ខ្ញុំទាមទារសុំបំបែកមន្ទីរ១៣ ហ្នឹងជាពីរ។ នេះ ជារឿងច្បាស់លាស់។ សូមអរគុណ ដែលបានបញ្ជាក់ឲ្យ-- អនុញ្ញាតឲ្យខ្ញុំបញ្ជាក់ច្បាស់លាស់អ៊ីចឹង។

[១៥:៣៩:៤៣]

**សៈ** បាទ សូមអរគុណ។ លោកបានជម្រាបជូនអង្គសវនាការអំមិញដែលហើយថា អ្នកដែលបញ្ជូនមក ម-១៣ នេះ គឺត្រូវតែសួរចម្លើយ ហើយកម្ទេច។ តើនៅមុននឹងកម្ទេច ពេលសួរចម្លើយនោះ តើមានការធ្វើទារុណកម្ម ឬក៏ធ្វើអ្វីដែរផ្សេងទៀតទេ?

**ឆៈ** មាន។ តែកាលណាយើងនេះហើយ គឺវាត្រូវតែធ្វើទារុណកម្ម។

**ស៖** តើវាល់ការសួរចម្លើយដោយមានទារុណកម្ម ហើយនិងការកម្ទេចហ្នឹង គឺមានបញ្ជាពីថ្នាក់លើណាមកដែរទេ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ហ្នឹងជាគោលនយោបាយរបស់បក្ស សុំទោស ខ្ញុំនិយាយលឿនណាស់។ គោលនយោបាយរបស់បក្ស អ្នកណាចូលតំបន់រំដោះ គឺត្រូវចាត់ទុកថាជាគិញ ហើយត្រូវតែសួរចម្លើយ ហើយកម្ទេច។ គោលនយោបាយមួយទៀត ទារុណកម្មអត់ប្រកែកទេ។ វន វ៉េត ផ្ទាល់ខ្លួនគាត់ គាត់ណែនាំខ្ញុំ។ របៀបធ្វើទារុណកម្មដែលគាត់ចូលចិត្តបំផុត គឺយកស្បោងប្លាស្ទិកទៅក្របពីលើក្បាល។ រួចឲ្យខ្ញុំទៅរកស្បោងប្លាស្ទិកឯណានៅអមលាំង វាអត់។

[១៥:៤១:០៩]

ហើយគាត់ថា មិត្តត្រូវមើលអាសរសៃកត្រង់ណោះ បើវាភ័យតក់ៗ អាហ្នឹងហើយមានខ្លួនគិញ។ អាហ្នឹងវិធីដែលគាត់បង្រៀនខ្ញុំ មានតែប៉ុណ្ណឹងឯង។ ដូច្នេះ សរុបមកឲ្យតែគិញ គឺកម្ទេច ទារុណកម្មចៀសមិនរួចទេ ឯណាខ្ញុំសុំលែងហ្នឹង គឺអត់មានទារុណកម្មទេ។

**ស៖** លោកបាននិយាយថា អំមិញអ្នកដែលចូលមក គឺតាមគោលការណ៍-- ជាគោលការណ៍បក្ស គឺត្រូវតែកម្ទេច។ តើលោកដឹងដោយរបៀបណាដែរ?

**ឆ៖** ឯកសារដែលខ្ញុំនិយាយ គោលនយោបាយមួយចំនួនរបស់បក្ស។

**ស៖** បាទ សូមអរគុណ។ លោកនៅចាំបានទេថា អ្នកដែលចូលនៅក្នុងម-១៣ ទាំងអស់ហ្នឹងត្រូវបានសម្លាប់ តើមានប៉ុន្មាននាក់ដែរ តើមានចាំទេ?

**ឆ៖** ខ្ញុំសូមនិយាយឲ្យស្រួលស្តាប់។ មិនដល់៣០០ទេ ២០០អីប៉ុណ្ណឹង លើសបន្តិចបន្តួច។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំបន្តទៅបន្ថែម ទាក់ទងទៅនឹងអាតួនាទីរបស់លោកនៅម-១៣តទៅទៀត។ នៅម-១៣ ហ្នឹង តើអ្នកណាដែលជាអ្នកគ្រប់គ្រងលោកផ្ទាល់តែម្តង តើអ្នកណាគេ?

**ឆ៖** ខាងការងារបក្ស ការងារមន្ទីរ វាមានប្រធានមន្ទីរ៣០៥។ ប៉ុន្តែឥឡូវគាត់ស្លាប់បាត់ទៅហើយ។ អ្នកការទូតម្នាក់ ឈ្មោះ រស់ ជាថូ ហៅ ជាតិ។ ឯចំណែកការងារខាងនគរបាល គឺ វន វ៉េត ដល់ក្រោយមក សុន សេន។

[១៥:៤៣:២៩]

**ស៖** បាទ សូមអរគុណ។ តើលោកដឹងពីតួនាទីរបស់ វន វ៉ន ហើយនិងសុន សេន គាត់មានតួនាទីអីដែរនៅក្នុងពេលនោះ?

**ឆ៖** ពេលនោះ ខ្ញុំដឹងថា វន វ៉េត សមាជិកមជ្ឈិម។ សុន សេន ក៏សមាជិកមជ្ឈិម។

**ស៖** លោកដឹងដែរទេថា ពួកគាត់ទាំងពីរនាក់ហ្នឹង គាត់មានទីកន្លែងនៅត្រង់ណាដែរ?

**ឆ៖** មន្ទីររបស់ វន វ៉េត នៅឃុំពាម ភូមិដូចជា ក្រាំងបេង ខ្ញុំភ្លេចទៅ។ ឯចំណែកក្រោយមកមន្ទីរ សុន សេន គាត់ប្រឡិមប្រឡុំនៅហ្នឹងសព្វថ្ងៃ។ កូនព្រៃ បាត១បន្តិច១ក្បែរវ៉ាស្នាច់ ស្ថានីយ៍ដំណាក់ស្នាច់ ស្ថានីយ៍រថភ្លើង។

**ស៖** នៅឃុំពាម ដែលលោកបានលើកអម្បាញ់មិញនៅក្រាំងដីអីហ្នឹង តើកន្លែងហ្នឹងនៅជិតមន្ទីរម-១៣ ដែរទេ?

[១៥:៤៥:00]

**ឆ៖** អត់ទេ។ ឃុំពាម ស្រុកកំពង់ត្រឡាចលើ ប៉ុន្តែឥឡូវនេះគេប្រើ ស្រុកសាមគ្គីមានជ័យ។ ភូមិក្រាំងបេង ឆ្ងាយពីមន្ទីរ១៣។

**ស៖** បាទ អរគុណ។ តើលោកធ្លាប់ទៅមូលដ្ឋានរបស់គាត់ទាំងពីរនាក់នុ៎ងដែរទេ?

**ឆ៖** ខ្ញុំទៅ វន វ៉េត ក៏ខ្ញុំទៅ សុន សេន ក៏ខ្ញុំទៅ។

**ស៖** បាទ អរគុណ។ នៅកាលដែលលោកបានទៅនៅកន្លែងនោះ តើលោកបានដឹងទេថា នៅកន្លែងនុ៎ងមានការប្រជុំស្អីដែរទេនៅពេលនុ៎ង?

**ឆ៖** មួយឆ្នាំលេខាភាគ គ្រប់ភាគ ហៅកម្មាភិបាលមន្ទីរក៏ដូចជាមូលដ្ឋានដែរទៅរៀនសូត្រវគ្គម្ដងគឺក្រោយពីគណៈកម្មាធិការភូមិភាគទៅរៀនជាមួយ ប៉ុល ពត។ ភាគច្រើន១រៀនទូវក្នុងរវាងខែ៦ ឬខែ៧ ដល់លេខាភាគអីត្រឡប់មកវិញហៅអ្នកខាងក្រោមទៅរៀន។ រៀនប្រហែលកន្លះខែចប់ ហើយក៏នាំគ្នាធ្វើការតស៊ូទៅទៀត។

[១៥:៤៧:០២]

**ស៖** បាទ សូមអរគុណ។ តើលោកបានយល់ដឹងអំពីការប្រជុំនោះយ៉ាងម៉េចខ្លះដែរ?

**ឆ៖** មិនប្រជុំទេ គឺរៀនផ្សព្វផ្សាយមាគ៌ាប្រចាំឆ្នាំ។ ឆ្នាំនេះទស្សនៈសភាពការណ៍វិវត្តន៍ទៅដល់ណា? ទិសវ៉ៃសម្រុករបស់យើងនៅសមរភូមិមុខយ៉ាងម៉េច? ហើយរៀបចំខាងសមរភូមិក្រោយយ៉ាងម៉េច? គោលជំហរសតិអារម្មណ៍ក្នុងជួរយើងចំបញ្ហាអីខ្លះ? នេះរៀងរាល់ឆ្នាំ អត់ខានទេ។ មួយឆ្នាំ១ប្រហែលជាកន្លះខែ១រាល់ឆ្នាំ។

**ស៖** តើលោកនៅចាំដែរទេ ថាការរៀននុ៎ង មានបង្រៀនពីគោលនយោបាយ ឬក៏ពីទាក់ទងនឹង

រចនាសម្ព័ន្ធអីរបស់បក្សអីយ៉ាងម៉េចដែរទេ?

**ឆៈ** ឯកសារដែលរៀន យើងអាចប្រមូលផ្តុំមកចែកជាបីជំពូក។ ឯកសារនយោបាយប្រមូលផ្តុំទាំងទស្សនៈសភាពការណ៍ ឆ្នាំនេះខ្លាំងវាយ៉ាងម៉េច? វិវត្តន៍ទៅយ៉ាងម៉េច? យើងវិវត្តន៍ទៅយ៉ាងម៉េច? ត្រូវតស៊ូយ៉ាងម៉េច? ទីពីរ ឯកសារសតិអារម្មណ៍ កម្ចាត់សតិអារម្មណ៍ស្អី សួនតួបុគ្គលអីៗវានៅក្នុងនុំងដែរ។ ហើយទីបី ឯកសារចាត់តាំង ប្រជុំជីវភាឲ្យទៀតទាត់យ៉ាងម៉េច ស្អីយ៉ាងម៉េច? ឯចំណែកមន្ទីរមួយៗប្រជុំជីវភាពរបស់គេទៅ ម-១៣ វាប្រជុំជីវភាពរបស់វាមក។ សាខាបក្សជាអ្នកគ្រប់គ្រង ហើយសូមបញ្ជាក់បន្ថែមបន្តិចទៀត។ ប្រចាំខែ បក្ខជនគ្រប់រូបត្រូវរៀនសូត្រទស្សនៈគោលជំហររបស់បក្សតាមទស្សនាវដ្តីទង់បដិវត្ត។ នេះគឺសូមបញ្ជាក់ប៉ុណ្ណឹង រៀនដោយខានមិនបាន។

[០៩:៤៩:៣៥]

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងតំណែងតួនាទីនៅ ម-១៣ ហ្នឹងតើអ្នកណាគេដែលមានតំណែងខ្ពស់ជាងគេបំផុតនៅក្នុងមន្ទីរ ម-១៣ ហ្នឹង?

**ឆៈ** ម-១៣ នេះវាគ្រប់គ្រងបានដោយសាខា មិនបានពេញសាខាមួយផង។ អ្នកដែលមានតំណែងខ្ពស់ជាងគេ គឺខ្ញុំ។ ឯចំណែកលេខាសាខាហ្នឹង គឺបងជាតិ វាអត់បានពេញមួយសាខាទេ។ វាមានតែបក្ខជនតែពីរនាក់ទេ គឺ ខ្ញុំ មិត្តស៊ុំ។

**សៈ** បាទ សូមអរគុណ។ ថាតើប្រតិបត្តិការរបស់មន្ទីរម-១៣ ហ្នឹងត្រូវបានបញ្ចប់នៅពេលណាដែរ លោកនៅចាំទេ?

**ឆៈ** ជាក់ស្តែងក្នុងការប្រតិបត្តិ អស់មានគិញផ្ញើទៅម-១៣ នៅថ្ងៃ១ មករា ១៩៧៥ គឺនៅថ្ងៃវ៉ៃសម្រុកតែម្តង។ មេខ្ញុំចេញទៅបញ្ជាសមរភូមិបាត់ហើយ ក៏ប៉ុន្តែ ក្រោយមកទើបបានគាត់ទៅជួបខ្ញុំនៅថ្ងៃ៣០ មេសា ឲ្យខ្ញុំបែងចែកមនុស្ស។ គាត់បែងចែកមនុស្សឲ្យខ្ញុំ ម្នាក់ទៅឯណាៗហ្នឹង។ ដូច្នេះ រំសាយអស់ គ្មានមនុស្សម-១៣ នៅដែទទេគឺនៅថ្ងៃ ៣០ មេសា។

**សៈ** បាទ សូមអរគុណ។ នៅថ្ងៃ៣០ មេសា គឺម-១៣ ត្រូវរំសាយអស់។

**ឆៈ** បាទ ។

**សៈ** ថាតើនៅពេលនោះ នៅពេលដែលរំសាយនោះមានអ្នកទោសនៅសល់ទេ?

**ឆៈ** រំសាយហ្នឹង គឺអស់ហើយ អត់មានទេ។ មានចំនួនដោះលែង មួយចំនួនឲ្យទៅ បងបេះខាងនគរបាលខាងត្រពាំងដោរ មួយចំនួនទៀតក៏បញ្ជាឲ្យកម្ទេច។ ភាគច្រើន ម-១៣(ខ) ដោះលែងទាំង

អស់ គ្នាប្រហែលជា៥០នាក់ ឬ១០០នាក់។

**ស៖** បាទ អរគុណ។ នៅក្នុងម-១៣ នេះតើលោកមានទទួលភារកិច្ចទាក់ទងទៅនឹងការអប់រំ ឬក៏បណ្តុះបណ្តាលដល់អ្នកដែលនៅទីនោះដែរទេ?

[១៥:៥២:០៥]

**ឆ៖** បក្ខជន វាត្រូវតែអប់រំកូនចៅវាអ៊ីចឹង។

**ស៖** បាទ ។ អ្នកដែលលោកបានអប់រំហ្នឹងជានរណាខ្លះ?

**ឆ៖** ខ្ញុំយកមកធ្វើការនៅស-២១ ទាំងអស់ហ្នឹង គ្នាប្រហែលជា១០នាក់។

**ស៖** ចុះអ្នកទោសនៅទីនោះ លោកបានអប់រំដល់អ្នកទោសដែរឬទេ នៅពេលនោះ?

**ឆ៖** ទៅអប់រំគ្នាម៉េច? មានតែប្រុងអប់រំហ្នឹងគឺ ពួកប្រមាណ៣០ប្លាយនាក់នុ៎ង ដែលប្រុងទុកឱ្យធ្វើស្រែនោះ។

**ស៖** ការដែលលោកធ្វើការអប់រំ ឬក៏បណ្តុះបណ្តាលដល់បុគ្គលិករបស់លោកនៅទីនោះ តើលោកអប់រំដោយយ៉ាងម៉េចដែរ?

**ឆ៖** ឯកសារមានស្រាប់។ សង្គ្រាមប្រជាជន សីលធម៌បដិវត្តន៍ គោលនយោបាយរបស់បក្ស។ គោលនយោបាយរបស់ហ្នឹង មិនមែនមានតែគោលនយោបាយរបស់គិញទេ។ វាមានគោលនយោបាយដីធ្លី វាមានគោលនយោបាយចំពោះជ័យភណ្ឌ យុទ្ធភណ្ឌ។ អ្នកណាទៅប៉ាន? កិបទុកជ័យភណ្ឌ និងយុទ្ធភណ្ឌ ព្រោះជ័យភណ្ឌ យុទ្ធភណ្ឌ ជារបស់បក្ស។ ដូច្នេះ គឺ សរុបមកគឺយើងអប់រំតាមឯកសារបក្ស។

**ស៖** បាទ សូមអរគុណ។ នៅៗក្នុងការបណ្តុះបណ្តាលនោះ តើលោកបានបង្ហាត់បង្រៀនអំពីបច្ចេកទេសនៃការសួរចម្លើយទៅដល់បុគ្គលិករបស់លោកដែរឬទេ នៅពេលហ្នឹង?

**ឆ៖** មាន។ មនុស្សដែលខ្ញុំប្រើជាប់លាប់ជាងគេហើយ ចេះតែយកទៅសួរជាមួយនឹងគ្នាហ្នឹង គឺមិត្តប៉ុន ឥឡូវគ្នាស្លាប់ហើយ។

**ស៖** បាទ អរគុណ។ ហើយការដែលលោកចេះបច្ចេកទេសនៃការសួរចម្លើយដែលអាចឱ្យលោកទៅបង្រៀនអ្នកផ្សេងបានហ្នឹង តើលោកចេះពីខាងណាមកដែរ?

**ឆ៖** សហព្រះរាជអាជ្ញាធ្លាប់ជ្រាបហើយ ថាខ្ញុំជាប់គុក។ គេសួរចម្លើយខ្ញុំ ហ្នឹងជាបញ្ហាមួយ។ បញ្ហាពីរ វាទៅហើយ វាទៅតិចៗទៅ។

**ស៖** បាទ អរគុណ។ នៅពេលនោះ តើមានប្រើពាក្យថា “កម្ទេច” ដែរឬទេនៅម-១៣ ហ្នឹង?

**ផៈ** នៅម-១៣ គេប្រើពាក្យ "ដោះស្រាយ"។

**សៈ** ពាក្យថា "ដោះស្រាយ" ហ្នឹងមានន័យម៉េចទៅ?

**ផៈ** យកទៅកម្ទេចហ្នឹង។

[១៥:៥៥:០៣]

**សៈ** ចុះពាក្យថា "កម្ទេច" ហ្នឹងមានន័យថាយ៉ាងម៉េចដែរ?

**ផៈ** "កម្ទេច" ហ្នឹងយកទៅវៃចោល តែប៉ុននុ៎ង។ នៅតែដដែលគ្រាន់តែប្តូរតែមួយម៉ាត់អ៊ីចេះ មួយម៉ាត់អ៊ីចឹង នៅតែធ្វើឲ្យគ្នាស្លាប់។

**សៈ** តាមរបៀបរបបគំរូដូចនៅម-១៣ ហ្នឹង តាមដែលលោកដឹងច្បាស់ តើប្រតិបត្តិការរបៀប អ៊ីចឹង តើមាននៅក្នុងមន្ទីរសន្តិសុខផ្សេងទៀតនៅក្នុងតំបន់រំដោះដែរទេ នៅមុនឆ្នាំ១៩៧៥?

**ផៈ** នៅខែ១២ ១៩៧០ ខ្ញុំដឹងហើយថា នៅខាងតំបន់២៥ មាននគរបាលមួយដឹកនាំដោយមិត្ត តេង ខាងតំបន់២៥។ ហើយដល់ចូលទៅនុ៎ងមាននគរបាលមួយនៅត្រពាំងជោរ ដឹកនាំដោយមិត្ត ខាន់ ឈ្មោះដើម តាំង ខែត វាមានមុនខ្ញុំរួចទៅហើយ។ ឯអាមន្ទីរភូមិភាគនិរតីហ្នឹង វាមាននគរបាលនិរតី របស់គេដឹកនាំដោយពួកហាណ្ឌយ ដល់ក្រោយមក តាម៉ុក គាត់រំសាយចោលទៅមន្ទីរនោះ។ ដូច្នេះ សរុបមកវិញនគរបាលនេះ វាជាវប្បធម៌ដែលបក្សបដិវត្តន៍ប្រើតាំងពីសម័យឥស្សរៈមក។ បច្ចេកទេស នៅដដែល ស្ទើរដដែលទាំងអស់។

[១៥:៥៦:៥៦]

**សៈ** តើលោកដឹងទេថា អ្នកដែលជាប់នៅក្នុងមន្ទីរសន្តិសុខតំបន់រំដោះនុ៎ង តើជាមនុស្សប្រភេទ ណាដែរ?

**ផៈ** ខ្ញុំ សំណួរនោះទូលាយណាស់។ ខ្ញុំសូមនិយាយតែខាងនៅខាង ម-១៣។ ម-១៣ មុនដំបូង គេបញ្ជូនមនុស្សពីសមរភូមិមុខមកឲ្យម-១៣ សួរចម្លើយ។ ដល់ក្រោយមក រវាងក្នុងឆ្នាំ១៩៧៣ ក្រោយ គ្រាប់បែក បេ-៥២ តាម៉ុក ចាប់ផ្តើមប្រជាជននៅមូលដ្ឋានហ្នឹងមកប្រគល់ឲ្យម-១៣។ ដូច្នេះ វាមានពីរ ប្រភេទហ្នឹង។ មួយ មនុស្សចូលតំបន់រំដោះ ពីរទៀតមនុស្សនៅក្នុងតំបន់រំដោះ។ ហ្នឹងខ្ញុំសូមបែងចែក បានតែពីរប៉ុណ្ណឹងទេ នៅទូទាំងប្រទេសមិនដឹងជាស្អីៗយ៉ាងម៉េចទេ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹង ម-១៣ ដែលជាគំរូ។ តើគំរូ ម-១៣ ហ្នឹងបានបន្ត រហូតទៅដល់មន្ទីរសន្តិសុខផ្សេងទៀត ដូចជា ស-២១ ឬព្រៃស អីដែរទេ?

**ឆ៖** គំរូហ្នឹងវាមានតាំងពីរសម័យឥស្សរៈមក។ ដូច្នេះបញ្ហា ម-១៣ ក៏ដោយ ព្រៃស ក៏ដូចជា ស-២១ រឿងនេះវា*ក្លាស៊ិក*។

**ស៖** អ៊ីចឹង ថាតើបច្ចេកទេសនៃការសួរចម្លើយ ទារុណកម្មអី គឺដូចគ្នានឹង ម-១៣ ដែរ ឬក៏យ៉ាងណាដែរ?

**ឆ៖** ខ្ញុំជឿថាដូចគ្នា។ បានជានិយាយថាខ្ញុំជឿ ពីព្រោះមន្ទីរនគរបាលទាំង១៩៦ នេះ អត់មានការទាក់ទងគ្នាទៅវិញទៅមកទេ។ ហើយនៅ ស-២១ នេះបច្ចេកទេសធ្វើទារុណកម្ម អនុញ្ញាតបួន។ ទីមួយ គឺវ៉ៃ ទីពីរ គឺវ៉ៃអាទូរស័ព្ទហ្នឹងឆក់ ទីបី គឺតាំងពីសម័យ វន វ៉េត ម្ល៉េះ គឺច្រកស្បោងកៅស៊ូ ហើយទីបួន គឺច្រកទឹកតាមច្រមុះ របៀបពួក ប៉េ.អេស ខ្មាំង ពួក ប៉េ.អេស លន់ នល់ គេធ្វើ។

**ស៖** បាទ សូមអរគុណ។ តើអ្នកដែលសួរចម្លើយធ្វើការនៅម-១៣ នោះ ធ្វើការនៅម-១៣ ជាមួយ លោកហ្នឹង តើក្រោយមក ត្រូវបានគេបញ្ជូនមកស-២១ ដើម្បីធ្វើការជាមួយលោកតទៀតដែរឬទេ?

**ឆ៖** កូនចៅខ្ញុំ ខ្ញុំយកមក។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន បើពិនិត្យមើលទៅលើពេលវេលា ហាក់បីដូចជាដល់ហើយ។ តើគួរសម្រាកសិនឬយ៉ាងណា? បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដូចគ្នានេះដែរ គឺបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់រង់ចាំសម្រាប់សាក្សី នៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

[១៦:០១:២៤]

ដោយឡែកបញ្ហាសម្លៀកបំពាក់ អង្គជំនុំជម្រះតម្រូវឲ្យប្រធានមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ផ្លាស់

ប្តូរសម្លៀកបំពាក់ កាំង ហ្កេកអ៊ាវ ហៅ ឌុច នូវសម្លៀកបំពាក់ជនស៊ីវិលធម្មតា នៅក្នុងអំឡុងពេលដែលបញ្ជូនលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច មកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ចាប់ពីព្រឹកស្អែកទៅរហូតដល់ចប់។ ដោយមិនអនុញ្ញាតឱ្យបង្ខំជនជាប់ចោទរូបនេះ-- ដល់សាក្សីរូបនេះ ស្លៀកសម្លៀកបំពាក់ឯកសណ្ឋានជាទណ្ឌិតទេ នៅក្នុងអំឡុងពេល ជនជាប់-- សាក្សីរូបនេះ ផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំដឹងថា ម៉ោងបួន ប៉ុន្តែខ្ញុំនិយាយដោយខ្លីទេ។ ខ្ញុំសូមអរគុណមេធាវីការពារក្តី អៀង សារី លើកបញ្ហាអម្បាញ់មិញ ជូនអង្គជំនុំជម្រះ វាជាបញ្ហាមួយសមស្រប។ អង្គជំនុំជម្រះបានជម្រាបរួចមកហើយ និងដឹងរួចមកហើយ។ យើងខ្ញុំបានផ្តល់ឯកសារទៅដល់ជនជាប់ចោទ ឱ្យជនជាប់ចោទពិនិត្យមើលឡើងវិញ ទៅលើឯកសារទាំងអស់នោះ ដែលយើងនឹងបង្ហាញជូននូវចំពោះមុខអង្គជំនុំជម្រះ។

[១៦:០២:៥០]

យើងមានសំណុំឯកសារនោះ ដែលវាមានភាពងាយស្រួលក្នុងពេលបង្ហាញនាពេលក្រោយ។ យើងមានឯកសារថតចម្លងទៅលើឯកសារនេះ ហើយផ្តល់ជូនទៅដល់មេធាវីការពារក្តី។ មេធាវី-- មន្ត្រីច្បាប់ក៏បានបញ្ជាក់ថា វាសមស្របដែលយើងខ្ញុំអាចផ្តល់ជូនទៅដល់មេធាវីការពារក្តី។ ឯកសារដែលយើងខ្ញុំផ្តល់ជូនទៅដល់មេធាវីការពារក្តីនោះ មានតែទំព័រផ្នែកខាងមុខតែប៉ុណ្ណោះ មិនមែនថាជាឯកសារពេញលេញនោះទេ។ ដូច្នេះ យើងខ្ញុំយល់ថា សមស្របសម្រាប់បង្ហាញជូនជនជាប់ចោទ។ នៅទីនេះ យើងមាន*បាញ់ឌី* ទាំងស្រុងតែម្តង។ គឺសម្រាប់ផ្តល់ជូនទៅដល់ខាងមេធាវីការពារក្តី ក៏ប៉ុន្តែយ៉ាងក៏ដោយ ប្រសិនបើចង់បាន គឺខ្ញុំផ្តល់ជូន។

**ប្រធានអង្គជំនុំ៖**

ឌុច អង្គុយសិនចុះ!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[១៦:០៣:៥៥]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំចង់ឆ្លើយតបចំពោះអ្វីដែលបានលើកឡើងពីខាងសហព្រះរាជអាជ្ញា។ វាសមស្រប ប្រសិនបើយើងធ្វើការសំណើបញ្ហាទាំងអស់នេះ ដោយមិនមានវត្តមានសាក្សី។ ហើយវាមិនសមរម្យទេ បើសិនបើសាក្សីរង់ចាំនៅទីនេះ ហើយយើងខ្ញុំលើកឡើងទៅលើចម្លើយតបទៅកាន់សហព្រះរាជអាជ្ញានោះ ដូច្នេះហើយ យើងគួរតែឲ្យសាក្សីនេះ ទៅបន្ទប់ឃុំឃាំងសិនទៅ។ ទើបយើងខ្ញុំអាចលើកការឆ្លើយតបបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សីទៅកាន់មន្ទីរឃុំឃាំងវិញចុះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំនឹងនិយាយដោយខ្លីទេ ដោយសារតែម៉ោងបួនហើយ ខ្ញុំដឹងដែរ។ ខ្ញុំសូមជំទាស់ទៅនឹងការផ្តល់ជូនសេចក្តីប្រកាសសាក្សីខ្លួនឯងជូនទៅដល់សាក្សី។ ខ្ញុំសូមជំទាស់ជាថ្មីម្តងទៀត ខ្ញុំសូមជំទាស់ជាពិសេសទៅលើបំណងរបស់សហព្រះរាជអាជ្ញា ដែលចង់ផ្តល់សាក្សីរូបនេះនូវបញ្ជីឯកសារ ជាពិសេសឯកសារទំព័រដំបូង ដែលគាត់ចង់ផ្តល់ជូនសាក្សីរូបនេះនៅពេលដេញដោល។

ដូចមុនដែរ ខ្ញុំសូមលើកឡើងសាជាថ្មី។ ដោយសារតែព័ត៌មានដែលយើងផ្តល់ជាមុនទៅដល់សាក្សីរូបនេះ គឺវាមិនជួយឲ្យសាក្សីចងចាំនោះទេ វានឹងធ្វើឲ្យមានការប្រឡាក់ប្រឡូកទៅនឹងព័ត៌មាននោះទៅវិញទេ។ វាពិបាកក្នុងការបំបែកចេញថា តើសាក្សីចាំចំណុចណាខ្លះ ហើយពិបាកសម្រាប់សាក្សីផ្តល់សក្ខីកម្ម ពីឯកសារដែលផ្តល់ជូនទៅដល់សាក្សី។ ប្រសិនបើខ្ញុំចាំមិនខុសនោះទេ សហព្រះរាជអាជ្ញាខ្លួនឯង នៅពេលមួយនោះទទួលស្គាល់ថា សាក្សីមួយនេះ។ ជាពិសេសនោះគឺថាវាមានការពិបាកក្នុងការរៀបចំសក្ខីកម្មរបស់ខ្លួន ឬក៏ថាសាក្សីរូបនេះនិយាយដោយខ្លួនឯង ឬក៏គាត់បានអានព័ត៌មានពីមុនយកមកនិយាយនាពេលក្រោយ។ ជាពិសេសក្រោយពីសាក្សីរូបនេះផ្តល់ជូននូវឯកសារសំណុំរឿងថតចម្លង។ ដូច្នេះហើយគឺខ្ញុំមានការស្នាក់ស្ទើរ ហើយជាការពិតខ្ញុំសូមជំទាស់ទៅនឹងការផ្តល់ឯកសារនេះទៅដល់សាក្សីតែម្តង។ ជាពិសេសបញ្ជីឯកសារ និងឯកសារថតចម្លងនៅក្នុងបញ្ជីនោះ មុនពេលដែលសាក្សីរូបនេះផ្តល់សក្ខីកម្ម។

[១៦:០៧:០៩]

ខ្ញុំជំរុញឲ្យសហព្រះរាជអាជ្ញានោះសួរសំណួរចំហទៅដល់សាក្សី មុនដែលគាត់បង្ហាញឯកសារទៅដល់សាក្សី ដើម្បីឲ្យសាក្សីនោះចងចាំឡើងវិញ។ ខ្ញុំមិនដឹងថាមានវិធីផ្សេងសម្រាប់សហព្រះរាជអាជ្ញាក្នុងការសួរ ឬក៏បង្ហាញយ៉ាងណានោះទេ ក្នុងការបង្ហាញទៅដល់សាក្សីដែលសហព្រះរាជអាជ្ញាចង់ស្តាប់សក្ខីកម្ម។ ដូច្នេះ នៅពេលនេះខ្ញុំជំរុញថាឲ្យសហព្រះរាជអាជ្ញាគួរតែសួរសំណួរបើកចំហជាមុនសិន។ បន្ទាប់មកហ្នឹងអាចធ្វើការបង្ហាញឯកសារទាំងអស់នោះ។ យើងខ្ញុំសូមបញ្ជាក់ឡើងវិញថាយើងខ្ញុំជំទាស់ចំពោះការផ្តល់ឯកសារទាំងអស់នោះទៅដល់សាក្សី។ សូមអរគុណ។

[១៦:០៧:៤៨]

**ប្រធានអង្គជំនុំ៖**

មេធាវីផ្សេងទៀត មានបញ្ហាអីទេ? មេធាវីការពារក្តី ចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ដើម្បីឲ្យបានចប់។

សូមអញ្ជើញ!

សូមលោក ផេសមិន! អ៎! លោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំមានស្ថានភាពមួយលំបាកដោយសារតែបទពិសោធន៍របស់ខ្ញុំនៅក្នុងតុលាការផ្សេង គឺបង្ហាញថា វាជាទម្លាប់ទៅហើយដែលអនុញ្ញាតឲ្យសាក្សីពិនិត្យទៅលើសេចក្តីប្រកាសរបស់ខ្លួនឡើងវិញបាន ហើយអាចពិនិត្យមើលឯកសារសាជាថ្មីបាន ដែលគម្រោងនឹងផ្តល់ជូនទៅដល់សាក្សីក្នុងតុលាការ។

ដូច្នេះ ខ្ញុំយល់នូវវិធីបច្ចេកទេសរបស់ខាងសហព្រះរាជអាជ្ញា ហើយក៏ខ្ញុំយល់អំពីការព្រួយបារម្ភរបស់ខាងមេធាវីការពារក្តី នួន ជា ដែលថាសាក្សីរូបនេះ គឺមានឯកសារមុនជាច្រើនរួចមកហើយ ហើយខ្ញុំគិតថាឯកសារទាំងអស់នេះ ក៏មិនជាការជះឥទ្ធិពលទៅដល់ការចងចាំរបស់សាក្សីនោះផងដែរ ហើយជាពិសេសចំពោះពេលដែលសាក្សីត្រូវបានតទល់ចំពោះមុខ។

ជំហររបស់យើងខ្ញុំនេះ គឺថាយើងខ្ញុំទុកឲ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេច។ ចំពោះយើងខ្ញុំវិញ គឺថាយើងខ្ញុំហ្នឹងក៏យល់ឃើញដូចទៅនឹងសហព្រះរាជអាជ្ញាដែលគាត់បានលើកឡើងផងដែរ។ សូមអរគុណ។

[១៦:០៩:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន! ពាក់ព័ន្ធទៅនឹងការសួរទៅលើ ការធ្វើបទអន្តរាគមន៍ពាក់ព័ន្ធទៅនឹងសាក្សី ឌុច នេះ ខ្ញុំបាទ សូមស្នើសុំលោកប្រធានអនុញ្ញាតឲ្យលោកស្រីមេធាវី លី ម៉ាញឿន ហើយនិងលោកមេធាវី ហុង គឹមសួន ដើម្បីធ្វើអន្តរាគមន៍។ ហើយពេលនេះលោកស្រីមានបំណងលើកយោបល់បន្តិចបន្តួច។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

**កញ្ញា លី ម៉ាញឿន៖**

សូមគោរពលោកប្រធាន! យើងជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលគាត់ចង់ផ្ដល់នូវ-- ដល់សាក្សីនូវកំណត់ហេតុសួរចម្លើយដែលបានចូលរួមពីលើកមុន ហើយសាក្សីរូបនេះក៏មានសិទ្ធិពិនិត្យមើលឯកសារទាំងអស់នោះផងដែរ។ ដោយពិចារណាទៅលើវិសាលភាពធំធេងនៃភស្តុតាងដែលលោក ឌុច មកផ្ដល់នៅក្នុងវគ្គសវនាការនេះ វាជាការសមស្របទាំងស្រុង ហើយជាពិសេសដោយសារតែវាជាផលប្រយោជន៍នៃសវនាការរបស់យើងឲ្យគាត់នោះមានសិទ្ធិពិនិត្យមើលសំណុំរឿង ហើយដើម្បីជាប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីខ្ញុំសូមលើកឡើងថាវាសមស្របទាំងស្រុង យ៉ាងហោចណាស់សាក្សីរូបនេះគួរតែទទួលបាននូវកំណត់ហេតុនៃការស្ដាប់ចម្លើយ និងសួរចម្លើយរបស់គាត់។ សូមអរគុណ។

[១៦:១១:១៥]

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីញ្ចៀម ស្មីត៖**

ខ្ញុំសូមលើកចំណុចមួយទៀតដែលថា ប្រសិនបើលើកអង្គច្បាប់នោះ គឺនឹងចំណាយពេល១០ ទៅ១៥នាទី។ មកទល់ពេលនេះ អង្គជំនុំជម្រះបានបង្គាប់បញ្ជាទៅដល់មន្ត្រីច្បាប់ផ្ដល់ជូនឯកសារនេះរួចទៅហើយ។ ហើយគឺយើងខ្ញុំក៏បានគិតអំពីការផ្ដល់ឯកសារផងដែរ។ មន្ត្រីច្បាប់គាត់បានផ្ញើជូនតាមអ៊ីម៉ែល

រួចហើយថា វាសម្រាប់កិច្ចដំណើរការនីតិវិធីឲ្យមានប្រសិទ្ធភាព។ គោលបំណងរបស់យើងខ្ញុំនេះក្នុងការផ្ដល់ឯកសារដើម្បីយើងចំណាយពេលតិចតួចចំពោះសាក្សីរូបនេះ ដោយសារតែសាក្សីរូបនេះគឺគាត់ចូលចិត្តមើលទៅលើឯកសារ។

[១៦:១២:០៥]

ដូចដែលអង្គជំនុំជម្រះ បានដឹងស្រាប់រួចមកហើយសាក្សីរូបនេះ គឺគាត់មានការចងចាំល្អណាស់ ក៏ប៉ុន្តែឯកសារដែលយើងផ្ដល់ជូននោះ គឺដើម្បីពន្លឿននីតិវិធី។ យើងគឺករណីមិនដូចទៅនឹងការលើកឡើង-- ដូចទៅនឹងជនជាប់ចោទ នួន ជា នោះទេ ដែលគាត់ថា នៅពេលដែលគាត់មើលឯកសារនេះ គាត់មិនអាចរកឃើញមិនអាចមើលបាន មិនទាន់បានមើល។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងខ្ញុំទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចទៅលើបញ្ហានេះ ហើយយើងគិតថាការស្ដាប់ចម្លើយទៅដល់សាក្សីរូបនេះប្រហែលជាអាចនឹងត្រូវចំណាយពេលប្រាំថ្ងៃឯណោះ។ ហើយបញ្ហានេះក៏មិនមែនជាបញ្ហាមួយដែលត្រូវសម្រេចនានានេះផងដែរ។ កាលដែលខ្ញុំចង់ផ្ដល់ឯកសារនេះ ដើម្បីធ្វើការសន្សំពេលវេលាតែប៉ុណ្ណោះ សូមអរគុណ។

[១៦:១៣:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៤:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីបានស្ដាប់ភាគីតំណាងសហព្រះរាជអាជ្ញាបានលើកឡើងពីសំណើសុំរបស់ខ្លួនផ្ដល់ឯកសារកំណត់ហេតុផ្សេងៗដែលបានសួរ ស្ដាប់ចម្លើយសក្ខីកម្មសាក្សី កាំង ហ្គេកអ៊ាវ ហៅឌុច កន្លងមកនៅក្នុងដំណាក់កាលស៊ើបអង្កេតមុនពេលផ្ដល់សក្ខីកម្ម ដើម្បីឲ្យសាក្សីរូបនោះបានពិនិត្យមើល និងរំឭកការចងចាំឡើងវិញនោះ គឺសមស្របជាមួយនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលបានសម្រេចកន្លងមករួចហើយអំពីបញ្ហានេះ។ ដូច្នេះអង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់សហព្រះរាជអាជ្ញាលើបញ្ហានេះ។ ហើយដោយឡែកបញ្ហាមួយទៀតដែលអង្គជំនុំជម្រះបានសម្រេចអម្បាញ់មិញនេះគឺការដែលតម្រូវឲ្យខាងប្រធានមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ផ្ដល់នូវការសម្លៀកបំពាក់ជាជនស៊ីវិលដល់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ក្នុងការចូលរួមផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាសាក្សីចាប់ពីពេលស្អែកទៅរហូតដល់ចប់កិច្ចដំណើរការនីតិវិធីនោះ គឺជាការគិតគូរពិចារណាសម្រេចដោយឆន្ទានុ

សិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដោយអង្គជំនុំជម្រះមិនបានទទួលព័ត៌មាន ឬក៏សំណើសុំពីភាគីណាមួយឡើងពីបញ្ហានេះ។ អ៊ីចឹងសូមបញ្ជាក់ឲ្យបានកាន់តែច្បាស់លាស់។

អនុរក្សមន្ទីរឃុំឃាំងនាំគាត់ ជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ សម្រាក៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញ ក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៦ នាទី)*